# កិច្ចតែងការបង្រៀន
# សំរាប់គ្រូសំរបសំរួល

## វគ្គបណ្តុះបណ្តាលគ្រូបង្គោលថ្នាក់ខេត្ត ស្តីពី
## ការត្រៀមបង្ការ និងកាត់បន្ថយគ្រោះភ័យនៃទឹកជំនន់


**សហការរៀបចំដោយៈ**

**មជ្ឈមណ្ឌលត្រៀមបង្ការគ្រោះមហន្តរាយអាស៊ី (ADPC)**

**គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ (NCDM)**



**ក្រោមៈ**

**ក្រោមផ្នែកទី៤ នៃកម្មវិធីគ្រប់គ្រងនិងកាត់បន្ថយគ្រោះទឹកជំនន់ របស់គណៈកម្មការទន្លេមេគង្គ**

**គាំទ្រមូលនិធិៈ**

**នាយកដ្ឋានជំនួយមនុស្សធម៌គណៈកម្មការអឺរ៉ុប (ECHO)**

**និង ភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេស ប្រទេសអាល្លឺម៉ង់ (GTZ)**

**ខែ កញ្ញា ២០០៩**

# មេរៀនទី ១៖ យន្តការស្ថាប័ន និង រចនាសម្ព័ន្ធគ្រប់គ្រងគ្រោះមហន្តរាយ របស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ

## ១. ចំណុចសំខាន់ៗក្នុងមេរៀន

១. គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ( *សមាសភាព, រចនាសម្ព័ន្ធ, តួនាទី និង ភារកិច្ច*)

២. គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត ( *សមាសភាព, រចនាសម្ព័ន្ធ, តួនាទី និង ភារកិច្ច*)

៣. គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយស្រុក ( *សមាសភាព, រចនាសម្ព័ន្ធ, តួនាទី និង ភារកិច្ច*)

៤. គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយឃុំ ( *សមាសភាព, រចនាសម្ព័ន្ធ, តួនាទី និង ភារកិច្ច*)

## ២. គោលបំណង

នៅចុងបញ្ចប់នៃមេរៀន សិក្ខាកាមនឹងកំនត់បានពី :

- យន្តការស្ថាប័ន, សមាសភាព និង រចនាសម្ព័ន្ធគ្រប់គ្រងគ្រោះមហន្តរាយគ្រប់កំរិត នៅក្នុងប្រទេសកម្ពុជា ។
- តួនាទី និង ភារកិច្ចរបស់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយ នៅប្រទេសកម្ពុជា ។

## ៣ រយៈពេល ០២ ម៉ោង និង ៣០នាទី

## ៤ សំភារៈឧបទេ្ទសន៍

- ក្តារខៀន
- ក្រដាសផ្ទាំងធំ
- ហ្វឺដសរសេរ ( ចំរុះពិណ)
- ស្កុតបិទក្រដាស
- ឯកសារមេរៀន
- ម៉ាស៊ីនបញ្ចាំងស្លែដ៏

## ៥ ដំណើរការ

**១. បង្ហាញគោលបំណងមេរៀន និង លទ្ធផលរំពឹងទុកដល់ សិក្ខាកាម**

១. អ្នកសំរបសំរួលបង្ហាញគោលបំណងមេរៀន និង លទ្ធផលរំពឹងទុកដល់សិក្ខាកាម ដោយបញ្ចាំងស្លាយ ឬ ក្រដាស់ធំ ឬ សរសេរដាក់លើក្តារខៀន ។ អ្នកសំរប សំរួលពន្យល់បន្ថែមបើមានការចាំបាច់ ។

*កំណត់ចំណាំ : សូមមើលមេរៀនក្នុងផ្នែកទី១ ទំព័រទី៤ និង បទបង្ហាញលេខ .....*

**២. ការរៀបចំ និងការបង្កើត គណៈកម្មាធិការគ្រប់គ្រង គ្រោះមហន្តរាយគ្រប់ថ្នាក់**

២. អ្នកសំរបសំរួលសួរសំនួរបំផុសគំនិត ដល់សិក្ខាកាមពីការរៀបចំ និង ការបង្កើតគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយនៅគ្រប់ថ្នាក់នៅកម្ពុជា ដោយប្រើសំនួរថា *តើលោក-អ្នកធ្លាប់បានដឹងពីគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយ ដែលបានបង្កើតឡើង ដោយរាជរដ្ឋាភិបាលកម្ពុជា ដែរឬទេ?*

៣. ទុកអោយសិក្ខាកាមឆ្លើយនឹងសំនួរខាងលើតាមការយល់ដឹងរបស់គេ ហើយអ្នកសំរបសំរួលត្រូវសរសេរ រាល់ចំលើយទាំងឡាយដែលសិក្ខាកាមបានឆ្លើយនឹងសំនួរ ខាងលើដាក់លើក្តារខៀន ឬ ផ្ទាំងក្រដាស់ធំ ។

៤. ក្រោយពីសិក្ខាកាមបានឆ្លើយនូវសំនួរខាងលើមក អ្នកសំរបសំរួលអាច ធ្វើការសង្ខេបលើចំលើយទាំងអស់នោះ ហើយ អ្នកសំរបសំរួលធ្វើការបង្ហាញជូនដល់សិក្ខាកាមពីការបង្កើត និង រៀបចំគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយនៅគ្រប់ថ្នាក់ ដោយចង្អុលពីឯកសារផ្លូវច្បាប់នានារួមមានអនុក្រិត ព្រះរាជក្រិត លិខិតបង្គាប់ការ ជាដើមនិងបង្ហាញពីរចនាសម្ព័ន្ធ សមាសភាព និង តួនាទី និង ការទទួលខុសត្រូវរបស់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយនៅគ្រប់ថ្នាក់ (ថ្នាក់ជាតិ ខេត្ត ស្រុក និង ឃុំ....)

៥. ក្រោយពីការធ្វើបទបង្ហាញមកសិក្ខាកាមអាចលើកជាសំនួរដើម្បីអោយបញ្ជាក់អោយបានច្បាស់ និង សិក្ខាកាមអាចផ្តល់ជាអនុសាសន៍ទាក់ទងនឹងខ្លឹមសារមេរៀននេះ ។

*សូមមើល និង ដកស្រង់ខ្លឹមសារមេរៀនលំអិតពីក្នុងមេរៀនទី ១ ស្តីពី "**យន្តការស្ថាប័ន និង ចនាសម្ពន្ធ័ គ្រប់គ្រងគ្រោះមហន្តរាយ នៅកម្ពុជា**" ទំព័រទី.........*

**៣. ការពិភាក្សា និង សំនួរ-ចំលើយ**

៦ រាល់សំនួរ និង អនុសាសន៏នានាដែលបានសិក្ខាកាមបានលើកឡើង អ្នកសំរបសំរួលត្រូវសរសេរលើក្តារខៀន ឬ ក្រដាស់ផ្ទាំងធំ ។

៧ ក្រោយពីបានទទួលសំនួរ និង អនុសាសន៏ទាំងអស់ហើយ អ្នកសំរបសំរួលអាចចាប់ផ្តើមឆ្លើយទាំងអស់នោះ ដោយបង្ហាញពីមូលដ្ឋានអោយបានច្បាស់លាស់ ។ ចំណែកអនុសាសនឹវិញ អ្នកសំរបសំរួលអាចដាក់ក្នុងការពិភាក្សា ជាមួយសិក្ខាកាម ឬ បើអាចឆ្លើយបានទៅនឹងអនុសាសន៏ទាំងនោះ អ្នកសំរបសំរួលអាចឆ្លើយតបបាន។

*កំនត់ចំណាំ : រាល់សំនួរ និង អនុសាសន៏នានាដែលបានលើកឡើងដោយសិក្ខាកាមនៅក្នុងវគ្គនិមួយៗ មានសារៈសំខាន់ណាស់ ដែលអាចយកមកកែលំអមេរៀននិមួយ ៗ។ ដូច្នេះអ្នកសំរបសំរួលត្រូវកត់ត្រាទុកទាំងអស់ ហើយយកមកកែលំអមេរៀនអោយ បានល្អ និង សមស្រប ។*

# មេរៀនទី ២៖ ការយល់ដឹងពីមូលដ្ឋានគ្រឹះនៃគ្រោះមហន្តរាយ

## ១. ចំណុចសំខាន់ៗក្នុងមេរៀន

១. វាក្យស័ព្ទ និង ពាក្យទាក់ទងនឹងការងារកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ

២. ការកើតឡើងនៃគ្រោះមហន្តរាយ និង ទំនាក់ទំនងរបស់វា

៣. មុខសញ្ញាគ្រោះថ្នាក់ និង គ្រោះមហន្តរាយមហន្តរាយនៅកម្ពុជា

## ២. គោលបំណង

នៅចុងបញ្ចប់នៃមេរៀនសិក្ខាកាម នឹងអាចកំនត់បានពី ៖

- និយមន័យ និង បរិបថនៃការប្រើប្រាស់ពាក្យបច្ចេកស័ព្ទ ឬ ពាក្យដែលទាក់ទងនឹងការងារកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ
- ការកើតឡើងនៃគ្រោះមហន្តរាយ និង ទំនាក់ទំនងរវាងមុខសញ្ញាគ្រោះថ្នាក់ ភាពងាយរងគ្រោះ និង សមត្ថភាព ។
- ប្រភេទមុខសញ្ញាគ្រោះថ្នាក់ និង គ្រោះមហន្តរាយធំ ដែលតែងតែកើតឡើងនៅកម្ពុជា។

## ៣. រយៈពេល៖ ០២ ម៉ោង

## ៤. សំភារៈឧបទ្ទេសន៍

- ក្តារខៀន
- ក្រដាសផ្ទាំងធំ
- ហ្វឺដសរសេរ (ចំរុះពិណ)
- ស្កុតបិទក្រដាស
- ឯកសារមេរៀន
- រូបភាពផ្សព្វផ្សាយ (ខិតប័ណ្ណអប់រំតូច-ធំ)
- ម៉ាស៊ីនបញ្ចាំងស្លែដ៍

## ៥. ដំណើរការ

**១. បង្ហាញគោលបំណងមេរៀន និង លទ្ធផលរំពឹងទុកដល់ សិក្ខាកាម**

១. អ្នកសំរបសំរួលនឹងបង្ហាញគោលបំណងមេរៀន និង លទ្ធផលរំពឹងទុករបស់ខ្លួន ក្រោយពីបានបង្រៀនមេរៀននេះ។ អ្នកសំរបសំរួលអាចសរសេរគោលបំណង និង លទ្ធផលរំពឹងទុកនេះ លើក្តារខៀន ឬ ក្រដាស់ផ្ទាំងធំ ឬ បញ្ចាំងស្លាយ ។

**២. វាក្យស័ព្ទ និង និយមន័យ**

២. អ្នកសំរបសំរួលនឹងលើកយកវាក្យស័ព្ទមួយចំនួន ដែលគេប្រើប្រាស់ទាក់ទងនឹងការងារគ្រប់គ្រងគ្រោះមហន្តរាយ មកពិភាក្សា និង ផ្លាស់ប្តូរការយល់ដឹងជាមួយសិក្ខាកាម។ ការពិភាក្សានេះ អាចធ្វើតាមវិធីសាស្ត្រច្រើន ដូចជា : (១)អាចលើកជាសំនួររកនិយមន័យពាក្យនិមួយៗ , (២) អាចពិភាក្សាជាដៃគូរកនិយមន័យពាក្យ , (៣) ឬ អាចបែងចែកក្រុមពិភាក្សាតូច ៗ (៤) ឬអាចផ្គូរផ្គងរវាងពាក្យ និង និយមន័យដែលបានរៀបចំរួចជាស្រេច ។ល។

៣. ក្រោយពីសិក្ខាកាមបានពិភាក្សាលើពាក្យ និង និយមន័យនៃពាក្យនិមួយៗហើយ អ្នកសំរបសំរួលត្រូវពិនិត្យមើលការអោយនិយមន័យរបស់សិក្ខាកាម និង ពន្យល់បន្ថែមលើខ្លឹមសារ អត្ថន័យ និង បរិបទនៃការប្រើប្រាស់ពាក្យនិមួយៗ អោយស៊ីនឹងការងារទាក់ទងនឹងគ្រោះមហន្តរាយ ។

៤. ក្រោយពីបានសិក្សាលើវាក្យស័ព្ទ និង និយមន័យមក អ្នកសំរបសំរួល ត្រូវលើយក ពាក្យ "**គ្រោះមហន្តរាយ** Disaster " និង និយមន័យរបស់វាមកធ្វើការពិភាក្សាបន្ថែមទៀត ដើម្បីរកអោយឃើញ និង ពិភាក្សាវែកញែកថាតើគ្រោះមហន្តរាយ វាកើតឡើង ដោយរបៀបណា និង កត្តា និង ធាតុផ្សំអ្វីខ្លះដែលបណ្តាលអោយកើតជា គ្រោះមហន្តរាយ។ ដើម្បីធ្វើការវិភាគលើដំណើរនៃការកើតឡើងនៃគ្រោះមហន្តរាយ អ្នកសំរបសំរួលត្រូវលើកយកពាក្យ និង និយមន័យរបស់វាបន្ថែមទៀតមក ធ្វើការសិក្សាដូចជាពាក្យ "**មុខសញ្ញាគ្រោះថ្នាក់** Hazard" "**ភាពងាយរងគ្រោះ** Vulnerability"

**៣ ការកើតឡើងនៃគ្រោះមហន្តរាយ**

និង "**សមត្ថភាព** Capacity"។ ដើម្បីអោយមានការយល់ច្បាស់ពីការកើតឡើងនៃគ្រោះមហន្តរាយនេះ អ្នកសំរបសំរួលត្រូវលើយកនិយមន័យ និង លក្ខណៈនៃពាក្យទាំងបួននេះមកពន្យល់ និង វែកញែកអោយដាច់ពីគ្នា ដោយលើកយកឧទាហរណ៍ជាក់ស្តែងមកបង្ហាញអោយបានច្បាស់លាស់ ។

*កំនត់ចំណាំ : សូមមើលមេរៀនក្នុងផ្នែកទី ១ ទំព័រទី៤ និង បទបង្ហាញ លេខ.......*

**៤. មុខសញ្ញាគ្រោះថ្នាក់និងគ្រោះមហន្តរាយនៅកម្ពុជា**

៥. ក្រោយពីសិក្សា និង បានបង្ហាញជូនពីការកើតឡើងនៃគ្រោះមហន្តរាយមក អ្នកសំរបសំរួលត្រូវភ្ជាប់ការយល់ដឹងរបស់សិក្ខាកាម ទៅនឹងព្រឹត្តិការណ៍នៃមុខសញ្ញាបង្ក គ្រោះមហន្តរាយសំខាន់ៗ ដែលកំពុងគំរាមកំហែង និង បង្កអោយមានគ្រោះមហន្តរាយនៅក្នុងកម្ពុជា ជាពិសេស លើកសំនួរបំផុសគំនិត ឬ បែងចែកក្រុមពិភាក្សា ដើម្បីពិភាក្សាលើសំនួរដូចតទៅ :

ក. តើមានមុខសញ្ញាបង្កគ្រោះមហន្តរាយអ្វីខ្លះនៅក្នុងប្រទេសកម្ពុជា ? តើវាតែងតែកើតឡើង និង បង្កការគំរាមកំហែង អ្វីខ្លះដល់អាយុជីវិតមនុស្ស សត្វ និង ដំណាំកសិកម្ម?

ខ. តាមការយល់ដឹងរបស់អ្នក តេតីប្រទេសកម្ពុជាយើងធ្លាប់ទទួលរងគ្រោះដោយសារគ្រោះមហន្តរាយធំៗអ្វីខ្លះ ? នៅឆ្នាំណាខ្លះ? តើវាបានបង្កការខូចខាតអ្វីខ្លះ? គិតជាតំលៃនៃការខូចខាតអស់ប្រហែល ប៉ុន្មាន?

៦. បែងចែកសិក្ខាកាមជាក្រុមពិភាក្សាតូចៗ ដើម្បីពិភាក្សាលើសំនួរទាំងពីរខាងលើក្នុងរយៈពេល ១៥ ឬ ២០ នាទី។

៧. ក្រោយពីក្រុមនិមួយៗពិភាក្សារួចហើយតំណាងក្រុមនិមួយៗ បង្ហាញលទ្ធផលពិភាក្សាដល់ក្រុមធំ។ នៅពេលដែលក្រុមនិមួយៗបង្ហាញលទ្ធផលរបស់ខ្លួន សមាជិកក្រុមដទៃអាចលើកជាសំនួរបញ្ជាក់បន្ថែម ឬ ផ្តល់ពតិមានបន្ថែម ឬ កែតំរូវពតិមាន ។ល។

ចំនែកអ្នកសំរបសំរួលវិញ ត្រូវសំរបសំរួលធ្វើយ៉ាងណាអោយការពិភាក្សា មានភាពសកម្ម និង ទទួលបានលទ្ធផលល្អ និង ប្រកបដោយការចូលរួម ចែករំលែកចំណេះ ដឹង បទពិសោធន៍ និង ពតិមាន។

៦. ក្រោយពីសិក្ខាកាមបានបង្ហាញពីលទ្ធផលរបស់ក្រុមនិមួយៗ និង ក្រោយពីមានការផ្លាស់ប្តូរបទពិសោធន៍ និង ចំណេះដឹងមក អ្នកសំរបសំរួល ត្រូវធ្វើបទបង្ហាញជូនសិក្ខាកាមពីប្រភេទមុខសញ្ញាបង្កគ្រោះមហន្តរាយ និង ប្រវត្តិនៃគ្រោះមហន្តរាយដែលប្រទេសកម្ពុជាធ្លាប់បានជួបប្រទះនៅពេលបច្ចុប្បន្ន និង ពេលអតីតកាល ដោយធ្វើ ការពន្យល់អោយបានច្បាស់លាស់ ដើម្បីទាញការយកចិត្តទុកដាក់របស់សិក្ខាកាម ដើម្បីគិតគូរកវិធានការណាសមស្រប សំរាប់អនុវត្តត្រៀមបង្ការ ការពារ និង គិតគូទុកជាមុនទប់ទុលនឹងមុខសញ្ញានានាដែលតែងតែគំរាមកំហែងដល់សហគមន៍ និង មូលដ្ឋានរបស់គេនៅពេលបច្ចុប្បន្ន និង ទៅអនាគត។

*កំនត់ចំណាំ : សូមមើលមេរៀនក្នុងផ្នែកទី២ ទំព័រទី.២២ និង បទបង្ហាញ លេខ......*

៨. ក្រោយពីការធ្វើបទបង្ហាញមកសិក្ខាកាមអាចលើកជាសំនួរដើម្បីអោយបញ្ជាក់អោយ បានច្បាស់ និង សិក្ខាកាមអាចផ្តល់ជាអនុសាសន៍ទាក់ទងនឹងខ្លឹមសារមេរៀននេះ។

**៤. ការពិភាក្សា និង សំនួរ-ចំលើយ**

៩. រាល់សំនួរ និង អនុសាសន៍នានាដែលបានសិក្ខាកាមបានលើកឡើង អ្នកសំរបសំរួលត្រូវសរសេរលើក្តារខៀន ឬ ក្រដាស់ផ្ទាំងធំ ។

១០. ក្រោយពីបានទទួលសំនួរ និង អនុសាសន៍ទាំងអស់ហើយ អ្នកសំរបសំរួលអាចចាប់ផ្តើមឆ្លើយទាំងអស់នោះ ដោយបង្ហាញពីមូលដ្ឋានអោយបានច្បាស់លាស់ ។ ចំណែកអនុសាសន៍វិញ អ្នកសំរបសំរួលអាចដាក់ក្នុងការពិភាក្សា ជាមួយសិក្ខាកាម ឬ បើអាចឆ្លើយបានទៅនឹងអនុសាសន៍ទាំងនោះ អ្នកសំរបសំរួលអាចឆ្លើយតបបាន។

១១.

កំនត់ចំណាំ : រាល់សំនួរ និង អនុសាសន៍នានាដែលបានលើកឡើងដោយសិក្ខាកាមនៅក្នុងវគ្គនិមួយៗ មានសារៈសំខាន់ណាស់ ដែលអាចយកមកកែលំអមេរៀននិមួយ ៗ។ ដូច្នេះអ្នកសំរបសំរួលត្រូវកត់ត្រាទុកទាំងអស់ ហើយយកមកកែលំអមេរៀនអោយ បានល្អ និង សមស្រប។

# មេរៀនទី ៣: ការយល់ដឹងពីការគ្រប់គ្រងគ្រោះមហន្តរាយ

## ១. ចំណុចសំខាន់ៗក្នុងមេរៀន

១. និយន័យនៃការគ្រប់គ្រងគ្រោះមហន្តរាយ

២. វដ្ត ឬ ដំណាក់កាលនៃការគ្រប់គ្រងគ្រោះមហន្តរាយ

*(ក) ត្រៀមបង្ការ, កាត់បន្ថយ និង ការពារ*

*(ខ) ឆ្លើយតប និង សង្គ្រោះ*

*(គ) ស្តារឡើងវិញ, ការកសាងឡើងវិញ និង ការអភិវឌ្ឍន៍*

## ២. គោលបំណង

នៅចុងបញ្ចប់នៃមេរៀន សិក្ខាកាមនឹងអាចកំនត់បានពី :

១. និយមន័យនៃការគ្រប់គ្រងគ្រោះមហន្តរាយ

២. វដ្ត ឬ ដំណាក់កាល និង សកម្មភាពដែលត្រូវអនុវត្តនៅក្នុងដំណាក់កាលនិមួយៗនៃការគ្រប់គ្រងគ្រោះមហន្តរាយ ។

## ៣. រយះពេលះ ០២ ម៉ោង

## ៤. សំភារះឧបទ្ទេសការ

- ក្តារខៀន
- ក្រដាសផ្ទាំងធំ
- ហ្វឺដសរសេរ (ចំរុះពិណ)
- ស្កុតបិទក្រដាស
- ឯកសារមេរៀន
- រូបភាពផ្សព្វផ្សាយ (ខិតប័ណ្ណអប់រំតូច-ធំ)
- វីដេអូស្ប៉ត់ (ការរស់នៅជាមួយទឹកជំនន់)
- ម៉ាស៊ីនបញ្ចាំងស្លៃដ៍

## ៥. ដំណើរការ

**១. បង្ហាញគោលបំណងមេរៀន និង លទ្ធផលរំពឹងទុកដល់ សិក្ខាកាម**

**២. និយន័យ**

**៣. ដំណាក់កាលនៃការគ្រប់គ្រងគ្រោះមហន្តរាយ (មុន -ក្នុង និង ក្រោយ)**

**៤. សកម្មភាពតាមដំណាក់កាលនីមួយៗនៃការគ្រប់គ្រងគ្រោះមហន្តរាយ:**

*- មុន: (ត្រៀមបង្ការ, កាត់បន្ថយ និង ការពារ)*

*- ក្នុងពេល (ឆ្លើយតប និង សង្គ្រោះ, ការព្យាករណ៍ និង ការផ្តល់ពិតមានជាមុន)*

*- ក្រោយពេល (ស្តារឡើងវិញ, ការកសាងឡើងវិញ និង ការអភិវឌ្ឍន៍)*

១. អ្នកសំរបសំរួលនឹងបង្ហាញគោលបំណងមេរៀន និង លទ្ធផលរំពឹងទុករបស់ខ្លួន ក្រោយពីបានបង្រៀនមេរៀននេះ។ អ្នកសំរបសំរួលអាចសរសេរគោលបំណង និង លទ្ធផលរំពឹងទុកនេះ លើក្តារខៀន ឬ ក្រដាស់ផ្ទាំងធំ ឬ បញ្ចាំងស្លាយ ។

*កំនត់ចំណាំ : សូមមើលមេរៀនក្នុងផ្នែកទី៣ ទំព័រទី ៣៤ និង បទបង្ហាញ លេខ.....*

២. ភ្ជាប់ទៅនឹងនិយមន័យនេះ អ្នកសំរបសំរួលត្រូវធ្វើបទបង្ហាញពីវដ្ត ឬ ដំណើរនៃការគ្រប់គ្រងគ្រោះមហន្តរាយ ដោយផ្តោតសំខាន់លើសកម្មភាព និង ការងារសំខាន់ៗទាំងឡាយណាសំរាប់អនុវត្តនៅក្នុងដំណាក់កាលទាំង ៣ គឺ ដំណាក់កាលមុន ដំណាក់កាលកំឡុងពេល និង ក្រោយពេល មានគ្រោះមហន្តរាយ។ ខាងក្រោមនេះ អ្នកសំរបសំរួលត្រូវលើកយកសកម្មភាព និង ការងារមកពន្យល់តាមដំណាក់កាលនិមួយៗ ដូចតទៅ :

៣. ក្នុងដំណាក់កាលមុនគ្រោះមហន្តរាយនេះ (ត្រៀមបង្ការ , ការពារ ) អ្នកសំរបសំរួលត្រូវលើកយកតែសកម្មភាព ការងារ និង វិធានការចាំបាច់ទាំងឡាយណាដែលត្រូវអនុវត្តនៅ ក្នុងដំណាក់កាលនេះ មកពន្យល់ និង លើកជាឧទាហរណ៍ជាក់ស្តែងមកបង្ហាញ និង ចែករំលែកបទពិសោធន៍ជាមួយសិក្ខាកាម ។

៤. ការដែលលើកយកសកម្មភាព ការងារ និង វិធានការទាំងអស់មកចែករំលែក អ្នកសំរបសំរួលត្រូវតែមានភាពឈ្លាសវៃ និង ប៉ិនប្រសប់ លើកយកតែអ្វីដែលមានភាពជាក់ស្តែង និង មានទំនាក់ទំនងនឹងបទពិសោធន៍ និង ការងារជាក់ស្តែងដែលសិក្ខាកាមធ្លាប់មានបទពិសោធន៍ ។

៥. ក្នុងដំណាក់កាលកំឡុងពេលមានគ្រោះមហន្តរាយនេះ (ឆ្លើយតប , សង្គ្រោះ) អ្នកសំរបសំរួលត្រូវ លើកយកតែសកម្មភាពការងារ និង វិធានការចាំបាច់ទាំងឡាយណាដែលត្រូវអនុវត្តនៅ ក្នុងដំណាក់កាលនេះ មកពន្យល់ និង លើកជាឧទាហរណ៍ជាក់ស្តែងមកបង្ហាញ និង ចែករំលែកបទពិសោធន៍ជាមួយសិក្ខាកាម ។

៦. ក្នុងដំណាក់កាលកំឡុងពេលមានគ្រោះមហន្តរាយនេះ (ឆ្លើយតប , សង្គ្រោះ) អ្នកសំរបសំរួលត្រូវ លើកយកតែសកម្មភាពការងារ និង វិធានការចាំបាច់ទាំងឡាយណាដែលត្រូវអនុវត្តនៅ ក្នុងដំណាក់កាលនេះ មកពន្យល់ និង លើកជាឧទាហរណ៍ជាក់ស្តែងមកបង្ហាញ និង ចែករំលែកបទពិសោធន៍ជាមួយសិក្ខាកាម ។

| | |
|---|---|
| **៣. វដ្ត ឬ ដំណើរការគ្រប់គ្រោះមហន្តរាយ**<br><br>**ក. ការត្រៀមបង្ការ, ការពារ**<br><br>**ខ. ការឆ្លើយតបការសង្គ្រោះ...**<br><br>**គ. ការស្តារ ឬការកសាងឡើងវិញ និង ការអភិវឌ្ឍន៍**<br><br>**៥. ការពិភាក្សា សំនួរ-ចំលើយ** | ៧. ការដែលលើកយកសកម្មភាព ការងារ និង វិធានការទាំងអស់មកចែករំលែក អ្នកសំរបសំរួលត្រូវតែមានភាពឈ្លាសវៃ និង ប៉ិនប្រសប់ លើកយកតែអ្វីដែលមានភាព ជាក់ស្តែង និង មានទំនាក់ទំនងនឹងបទពិសោធន៍ និង ការងារជាក់ស្តែងដែលសិក្ខាកាមធ្លាប់មានបទពិសោធន៍ ។<br><br>៨. ក្នុងដំណាក់កាលកំឡុងពេលមានគ្រោះមហន្តរាយនេះ (ការស្តារ ឬ ការកសាងឡើង និង ការអភិវឌ្ឍន៍) អ្នកសំរបសំរួលត្រូវលើកយកតែសកម្មភាព ការងារ និង វិធានការចាំបាច់ទាំងឡាយណា ដែលត្រូវអនុវត្តនៅ ក្នុងដំណាក់កាលនេះ មកពន្យល់ និង លើកជាឧទាហរណ៍ ជាក់ស្តែងមកបង្ហាញ និង ចែករំលែកបទពិសោធន៍ជាមួយសិក្ខាកាម ។ ការដែលលើកយកសកម្មភាព ការងារ និង វិធានការទាំងអស់មកចែករំលែក អ្នកសំរបសំរួលត្រូវតែមានភាពឈ្លាសវៃ និង ប៉ិនប្រសប់ លើកយកតែអ្វីដែលមានភាពជាក់ស្តែង និង មានទំនាក់ទំនងនឹងបទពិសោធន៍ និង ការងារជាក់ស្តែងដែលសិក្ខាកាមធ្លាប់មានបទពិសោធន៍ ។<br><br>៩. ក្រោយពីការធ្វើបទបង្ហាញមកសិក្ខាកាមអាចលើកជាសំនួរដើម្បីអោយបញ្ជាក់អោយបានច្បាស់ និង សិក្ខាកាមអាចផ្តល់ជាអនុសាសន៍ទាក់ទងនឹងខ្លឹមសារមេរៀននេះ ។<br><br>១០. រាល់សំនួរ និង អនុសាសន៍នានាដែលបានសិក្ខាកាមបានលើកឡើង អ្នកសំរបសំរួលត្រូវសរសេរលើក្តារខៀន ឬ ក្រដាស់ផ្ទាំងធំ ។<br><br>១១. ក្រោយពីបានទទួលសំនួរ និង អនុសាសន៍ទាំងអស់ហើយ អ្នកសំរបសំរួលអាចចាប់ផ្តើមឆ្លើយទាំងអស់នោះ ដោយបង្ហាញពីមូលដ្ឋានអោយបានច្បាស់លាស់ ។ ចំណែកអនុសាសន៍វិញ អ្នកសំរបសំរួលអាចដាក់ក្នុងការពិភាក្សា ជាមួយសិក្ខាកាម ឬ បើអាចឆ្លើយបានទៅនឹងអនុសាសន៍ទាំងនោះ អ្នកសំរបសំរួលអាចឆ្លើយតបបាន ។<br><br>*កំនត់ចំណាំ : រាល់សំនួរ និង អនុសាសន៍នានាដែលបានលើកឡើងដោយសិក្ខាកាមនៅក្នុងវគ្គនិមួយៗ មានសារៈសំខាន់ណាស់ ដែលអាចយកមកកែលំអមេរៀននិមួយ ៗ ។ ដូច្នេះអ្នកសំរបសំរួលត្រូវកត់ត្រាទុកទាំងអស់ ហើយយកមកកែលំអមេរៀនអោយ បានល្អ និង សមស្រប ។* |

# មេរៀនទី ៤:  ការប៉ាន់ប្រមាណពីមុខសញ្ញាគ្រោះថ្នាក់ ភាពងាយរងគ្រោះ និង សមត្ថភាព

## ១. ចំណុចសំខាន់ៗនៃមេរៀន

ក. គំនិតទូទៅនៃការប៉ាន់ប្រមាណពី មុខសញ្ញាគ្រោះថ្នាក់, ភាពងាយរងគ្រោះ និង សមត្ថភាព

ខ. ធាតុសំខាន់ៗរបស់មុខសញ្ញាគ្រោះថ្នាក់, ភាពងាយរងគ្រោះ និង សមត្ថភាព

គ. ជំហាននៃការអនុវត្តន៍របស់ មុខសញ្ញាគ្រោះថ្នាក់, ភាពងាយរងគ្រោះ និង សមត្ថភាព

ឃ. របៀបធ្វើការប៉ាន់ប្រមាណពីមុខសញ្ញាគ្រោះថ្នាក់, ភាពងាយរងគ្រោះ និង សមត្ថភាព

## ២. គោលបំណង

នៅចុងបញ្ចប់នៃមេរៀន សិក្ខាកាមទាំងអស់នឹងបានយល់ដឹងអំពី:

- ស្គាល់ពីការប៉ាន់ប្រមាណរបស់ មុខសញ្ញាគ្រោះថ្នាក់, ភាពងាយរងគ្រោះ និង សមត្ថភាព ។
- ជំហាននៃការអនុវត្តន៍របស់ មុខសញ្ញាគ្រោះថ្នាក់, ភាពងាយរងគ្រោះ និង សមត្ថភាព ។
- ស្គាល់ពីឧបករណ៍សំខាន់ៗសំរាប់ប្រើប្រាស់ក្នុងការប៉ាន់ប្រមាណមុខសញ្ញាគ្រោះថ្នាក់, ភាពងាយរងគ្រោះ និង សមត្ថភាព ។
- អាចយកទៅអនុវត្តបាននៅក្នុងសហគមន៍របស់ខ្លួន ប្រកបដោយប្រសិទ្ធិភាព ។

## ៣. រយៈពេល:  ០៣ ម៉ោង (ដោយឡែក ក្នុងករណីមានការអនុវត្តទីវាល ត្រូវការពេលវេលាយ៉ាងតិច ០១ថ្ងៃ)

## ៤. សំភារៈឧបទេ្ទសន៍

- ក្តារខៀន
- ក្រដាសផ្ទាំងធំ
- ហ្វឺដសរសេរ (ចំរុះពណ៌)
- ស្កុតបិទក្រដាស
- ឯកសារមេរៀន
- សៀវភៅទិន្នន័យភូមិ/សហគមន៍ផ្សេងៗ
- ម៉ាស៊ីនបញ្ចាំងស្លែដ៏

## ៥. ដំណើរការ

**១. បង្ហាញគោលបំណងមេរៀន និង លទ្ធផលរំពឹងទុកដល់ សិក្ខាកាម**

១. អ្នកសំរបសំរួលនឹងបង្ហាញគោលបំណងមេរៀន និង លទ្ធផលរំពឹងទុករបស់ខ្លួន ក្រោយពីបានបង្រៀនមេរៀននេះ។ អ្នកសំរបសំរួលអាចសរសេរគោលបំណង និង លទ្ធផលរំពឹងទុកនេះ លើក្តារខៀន ឬ ក្រដាស់ផ្ទាំងធំ ឬ បញ្ចាំងស្លាយ ។

**២. គំនិតទូទៅនៃការប៉ាន់ប្រមាណមុខសញ្ញាគ្រោះមហន្តរាយ ភាពងាយរងគ្រោះ និង សមត្ថភាព**

២. អ្នកសំរបសំរួលត្រូវលើកជាសំណួរបំផុសទៅកាន់សិក្ខាកាម ដើម្បីពួកគេបានចូលរួមមតិយោបល់ផ្សេងៗទាក់ទិននឹងន័យ ថាតើអ្វីទៅជាការប៉ាន់ប្រមាណមុខសញ្ញាគ្រោះថ្នាក់?, ភាពងាយរងគ្រោះ? និង សមត្ថភាព? ហេតុអ្វីបានជាចាំបាច់ធ្វើការប៉ាន់ប្រមាណ វាមានសារៈសំខាន់យ៉ាងណា HVCA?

**៣. ធាតុសំខាន់នៃ ការប៉ាន់ប្រមាណមុខសញ្ញាបង្កគ្រោះមហន្តរាយ ភាពងាយរងគ្រោះ និង សមត្ថភាព**

៣. ក្រោយពីសរុបមតិចូលរួមរបស់សិក្ខាកាមរួចមក បទបង្ហាញខ្លី ពីធាតុ និងប្រភេទឧបករណ៍សំរាប់ធ្វើការប៉ាន់ប្រមាណ ក៏ដូចជាជំហាននៃការអនុវត្តរបស់ HVCA ត្រូវបានបង្ហាញ។ ក្នុងនោះអ្នកសំរបសំរួល ត្រូវសង្កត់ធ្ងន់ទៅលើប្រភេទនៃឧបករណ៍នីមួយៗ និងសារៈប្រយោជន៍របស់វា ។ ចំពោះឧបករណ៍ HVCA ដែលគេនិយមប្រើប្រាស់ ដូចជាៈ ការគូសផែនទី, ប្រវត្តិសហគមន៍, ការសំភាសន៍ និង ប្រតិទិនរដូវកាល ...ជាដើម ។

*កំនត់ចំណាំ : សូមមើលមេរៀនក្នុងផ្នែកទី៤ ទំព័រទី៤២ និង បទបង្ហាញ លេខ....*

**៤. ឧបករណ៍នានាសំរាប់ធ្វើការប៉ាន់ប្រមាណ**

**៥. របៀបធ្វើការប៉ាន់ប្រមាណពីមុខសញ្ញាគ្រោះថ្នាក់, ភាពងាយរងគ្រោះ និង សមត្ថភាព**

៤. ដើម្បីឱ្យសិក្ខាកាមកាន់តែយល់ដឹងច្បាស់លាស់ អ្នកសំរបសំរួលអាចបែងចែកសិក្ខាកាមជាក្រុមពិភាក្សាតូចៗពី ០៤ ទៅ ០៥ក្រុម ផ្អែកតាមចំនួននៃមុខសញ្ញាគ្រោះថ្នាក់ដែលបានកំណត់ (ទឹកជំនន់ ខ្យល់ព្យុះ រាំងស្ងួត សត្វល្អិត បំផ្លាញដំណាំ......) និង មានទំរង់គំរូ ឬបញ្ជីសំណួរចែកជូនតាមក្រុមនីមួយៗ សំរាប់ធ្វើការពិភាក្សានៅក្នុងថ្នាក់ ឬចុះអនុវត្តផ្ទាល់នៅតាមទីវាល ដោយការប្រើប្រាស់ឧបករណ៍ទាំងអស់ខាងលើ ឬអនុវត្ត តែឧបករណ៍ណាមួយក្នុងចំនោមឧបករណ៍ទាំងអស់ក៏បាន គឺអាស្រ័យទៅនឹងតម្រូវការ និង ពេលវេលាជាក់ស្តែង) ។

៥. ក្រោយពីក្រុមនិមួយៗបានពិភាក្សារួចមក ឬបានបំពេញលើការអនុវត្តសាកល្បងទីវាលចប់ តំណាងក្រុមនិមួយៗត្រូវមកបង្ហាញលទ្ធផលនៃ ការពិភាក្សារបស់ខ្លួន។ កំនត់សំគាល់ៈ អ្នកសំរបសំរួលនឹងកំនត់ពេលវេលាសមស្រប ដើម្បីអោយក្រុមនិមួយៗបង្ហាញលទ្ធផល និង ឆ្លើយសំនួរផ្សេងពីក្រុមធំ ឬ បំពេញបន្ថែមលើពិតមានដែលបានចូលរួមពីក្រុមធំ ។

# មេរៀនទី ៥: កម្មវិធីត្រៀមបង្ការគ្រោះទឹកជំនន់

## ១. ចំណុចសំខាន់ៗក្នុងមេរៀន

១. គំនិតទូទៅនៃការត្រៀមបង្ការគ្រោះមហន្តរាយ

២. គំនិតទូទៅនៃផែនការត្រៀមបង្ការគ្រោះទឹកជំនន់

៣. ផ្នែកសំខាន់ៗ និង ទំរង់គំរូនៃផែនការត្រៀមបង្ការគ្រោះទឹកជំនន់

៤. ដំណើរការនៃការរៀបចំផែនការត្រៀមបង្ការគ្រោះទឹកជំនន់

## ២. គោលបំណង

នៅចុងបញ្ចប់នៃមេរៀន សិក្ខាកាមនឹងអាចកំនត់បានពី :

- គំនិតទូទៅ និងសារៈសំខាន់នៃការត្រៀមបង្ការគ្រោះមហន្តរាយ
- ផ្នែកសំខាន់ៗ និង ទំរង់គំរូនៃផែនការត្រៀមបង្ការគ្រោះទឹកជំនន់
- អាចរៀបចំបាននូវផែនការត្រៀមបង្ការ ផ្អែកលើពតមានទាក់ទងនឹងមុខសញ្ញាគ្រោះថ្នាក់ ភាពងាយរងគ្រោះ និង សមត្ថភាព ដែលបានប្រមូល និង ការវិភាគយ៉ាងល្អិតល្អន់ជាមួយសហគមន៍

## ៣. រយៈពេល: ០២ ម៉ោង

## ៤. សំភារៈឧបទ្ទេសន៍

- ក្តារខៀន
- ក្រដាសផ្ទាំងធំ
- ហ្វឹដសរសេរ (ចំរុះពិណ)
- ស្កុតបិទក្រដាស
- ឯកសារមេរៀន
- សៀវភៅផែនការត្រៀមបង្ការទឹកជំនន់ (គំរូ)
- ម៉ាស៊ីនបញ្ចាំងស្លែដ៍

## ៥. ដំណើរការ

**១. បង្ហាញគោលបំណងមេរៀន និង លទ្ធផលរំពឹងទុកដល់ សិក្ខាកាម**

១. អ្នកសំរបសំរួលនឹងបង្ហាញគោលបំណងមេរៀន និង លទ្ធផលរំពឹងទុករបស់ខ្លួន ក្រោយពីបានបង្រៀនមេរៀននេះ។ អ្នកសំរបសំរួលអាចសរសេរគោលបំណង និង លទ្ធផលរំពឹងទុកនេះ លើក្តារខៀន ឬ ក្រដាស់ផ្ទាំងធំ ឬ បញ្ចាំងស្លាយ ។

**២. គំនិតទូទៅនៃត្រៀមបង្ការគ្រោះមហន្តរាយ**

២. មុនពេលចាប់ផ្តើមសិក្សាពីមេរៀនទី ៥ នេះ អ្នកសំរបសំរួលត្រូវរិះរកវិធីសាស្រ្ត ដើម្បីទាញការយកចិត្តទុកដាក់របស់សិក្ខាកាមអោយផ្តោតសំខាន់លើការត្រៀមបង្ការនៅមុនពេលមានគ្រោះមហន្តរាយកើតឡើង ធ្វើយ៉ាងណាអោយសិក្ខាកាមផ្សាភ្ជាប់នូវអ្វីដែលគេបានរៀនសូត្រពីពីមេរៀនទី ៣ និង មេរៀនទី ៤ ដោយលើកឡើងនូវចំណុចគន្លឹះសំខាន់ៗមកបញ្ជាក់ថា ការងារឆ្លើយតប សង្រ្គោះបន្ទាន់ និង ការស្តារឡើងវិញ ឬ ជួសជុលឡើងវិញបានឆាប់រហ័ស និង មានប្រសិទ្ធិភាព ដរាបណាអាជ្ញាធរ និង សហគមន៍ដែលរស់នៅតំបន់ប្រឈមមុខនឹងគ្រោះមហន្តរាយមានកម្មវិធី ឬ ផែនការត្រៀមបង្ការមួយច្បាស់លាស់ជាមុន។ ព្រោះកម្មវិធី ឬ ផែនការត្រៀមបង្ការបានកំនត់ពីវិធានការណ៍ត្រូវធ្វើនៅមុនពេល កំឡុងពេល និង ក្រោយពេលមានគ្រោះមហន្តរាយ និង បានកំនត់ពីតួនាទី និង ការទទួលខុសត្រូវរបស់ស្ថាប័ន និង អ្នកពាក់ព័ន្ធរួចជាស្រេច ។ កម្មវិធី ឬ ផែនការអាចជួយពង្រឹងនូវកិច្ចសហប្រតិបត្តិការ និង ការសំរបសំរួល ជាពិសេសវាអាចជួយក្នុងការស្វែងរកធនធាន និង ការគាំទ្រផ្សេងៗ សំរាប់អនុវត្តនៅកំឡុងពេល និង ក្រោយពេលមានគ្រោះមហន្តរាយ ។

៣. ភ្ជាប់ទៅនឹងការទាញការចិត្តទុកដាក់នេះ អ្នកសំរបសំរួលអាចធ្វើបទបង្ហាញខ្លីពីគំនិតទូទៅ និង សារៈសំខាន់នៃការត្រៀមបង្ការគ្រោះមហន្តរាយជាមុន មុននឹងចូលដល់ខ្លឹមសារសំខាន់នៃកម្មវិធីត្រៀមបង្ការគ្រោះទឹកជំនន់ ដែលជាចំនុចគន្លឹះនៃមេរៀនទី ៥ នេះ ។

*កំនត់ចំណាំ : សូមមើលមេរៀនក្នុងផ្នែកទី៥ ទំព័រទី៤៩ និង បទបង្ហាញ លេខ....*

**៣. គំនិតទូទៅនៃផែនការត្រៀមបង្ការគ្រោះទឹកជំនន់**

៤. ភ្ជាប់ទៅនឹងគោលគំនិតសំខាន់ៗនៃការត្រៀមបង្ការគ្រោះមហន្តរាយខាងលើ អ្នកសំរបសំរួលអាចធ្វើបទបង្ហាញខ្លីផងដែរ ពីគំនិតទូទៅនៃផែនការត្រៀមបង្ការគ្រោះ ទឹកជំនន់ ដោយផ្តោតសំខាន់លើ "អ្វីជាផែនការត្រៀមបង្ការគ្រោះទឹកជំនន់?" និង "តើផែនការត្រៀមបង្ការគ្រោះទឹកជំនន់នេះមានសារៈសំខាន់អ្វីខ្លះ? "

**៤. ផ្នែកសំខាន់ ៗ និង ទំរង់គំរូនៃផែនការត្រៀមបង្ការគ្រោះទឹកជំនន់**

៥. បន្ទាប់ពីធ្វើបទបង្ហាញខ្លីពីគំនិតទូទៅនៃផែនការត្រៀមបង្ការគ្រោះទឹកជំនន់មក អ្នកសំរបសំរួលត្រូវដឹកនាំអោយមានការចែករំលែក និង ផ្លាស់ប្តូរបទពិសោធន៏ជុំវិញផ្នែកសំខាន់នៃផែនការទូទៅ ផ្អែកតាមបទពិសោធន៏របស់សិក្ខាកាមដែលគេមាន។ ដើម្បីទាញបាននូវបទពិសោធន៏សំខាន់ៗរបស់សិក្ខាកាម អ្នកសំរបសំរួលត្រូវបែងចែកសិក្ខាកាមជា៣ ឬ ៤ ក្រុមតូចៗ ដើម្បីពិភាក្សាលើសំនួរដូចតទៅ :

*ក. ផ្អែកតាមបទពិសោធន៏របស់អ្នក តើផែនការមានផ្នែកសំខាន់ៗរបស់វាអ្វីខ្លះ?*

*ខ. តើត្រូវរៀបចំផែនការយ៉ាងដូចម្តេចដើម្បីអោយកម្មវិធី ឬ ផែនការអាចឆ្លើយតបទៅនឹងសេចក្តីត្រូវការពិតប្រាកដរបស់អ្នកទទួលផល? និង ដើម្បីអោយផែនការងាយស្រួលអនុវត្ត?*

*គ. តើអ្នកណាជាអ្នកដឹកនាំ និង ចូលរួមក្នុងការរៀបចំកម្មវិធី ឬ ផែនការ?*

៦. ក្រុមនិមួយៗអាចពិភាក្សាលើសំនួរខាងលើ រយៈពេលពី២០-២៥ នាទី។ ក្រោយពីបានពិភាក្សារួចមក តំណាងក្រុមនិយមួយៗ ត្រូវបង្ហាញពីលទ្ធផលនៃការពិភាក្សារបស់ខ្លួនដល់ក្រុមដទៃ។ នៅពេលដែលក្រុមនិមួយបង្ហាញលទ្ធផលនេះ អ្នកសំរបសំរួលត្រូវសំរបសំរួលអោយមានការពិភាក្សាលើលទ្ធផលរបស់ក្រុមនិមួយៗ ដោយធ្វើអោយមានជាសំនួរបញ្ជាក់ និង ផ្តល់ជាអនុសាសន៏ ពីសមាជិកក្រុមដទៃទៀត។

៧. ក្រោយពីក្រុមនិមួយៗពិភាក្សា និង បង្ហាញលទ្ធផលមក អ្នកសំរបសំរួលត្រូវធ្វើការបូកសរុបលើលទ្ធផលនៃការពិភាក្សា និង ធ្វើបទបង្ហាញខ្លីពីផ្នែកសំខាន់ៗ និង ទំរង់គំរូ

៨. ក្រោយពីក្រុមនិមួយៗបានធ្វើលំហាត់នេះរួមមក តំណាងក្រុមនិមួយៗនឹងបង្ហាញលទ្ធផលនៃការពិភាក្សាដល់សិក្ខាកាមទាំងអស់។ នៅពេលដែលក្រុមនិមួយៗបង្ហាញលទ្ធផលនេះ អ្នកសំរបសំរួលត្រូវសំរបសំរួលធ្វើយ៉ាងណាអោយមានជាសំនួរ និង ការផ្តល់អនុសាសន៏នានាពីសមាជិកក្រុមដទៃ។

នៅពេលក្រុមទាំងអស់បង្ហាញលទ្ធផលចប់សព្វគ្រប់ អ្នកសំរបសំរួលត្រូវធ្វើការបូកសរុប និង ផ្តល់អនុសាសន៍ ឬ ធ្វើការកែលំអបន្ថែមលើលទ្ធផលនៃការពិភាក្សា និង ធ្វើការបូកសរុប ។

៩. ជាចុងក្រោយ អ្នកសំរបសំរួលត្រូវផ្តល់ឱកាសអោយសិក្ខាកាមអាចលើកជាសំនួរ ដើម្បីអោយបញ្ជាក់អោយបានច្បាស់ និង សិក្ខាកាមអាចផ្តល់ជាអនុសាសន៍ទាក់ទងនឹងខ្លឹមសារមេរៀននេះ ។

១០. រាល់សំនួរ និង អនុសាសន៍នានាដែលបានសិក្ខាកាមបានលើកឡើង អ្នកសំរបសំរួលត្រូវសរសេរលើក្តារខៀន ឬ ក្រដាស់ផ្ទាំងធំ ។

**៥. ការពិភាក្សា និង សំនួរ-ចំលើយ**

១១. ក្រោយពីបានទទួលសំនួរ និង អនុសាសន៍ទាំងអស់ហើយ អ្នកសំរបសំរួលអាចចាប់ផ្តើមឆ្លើយទាំងអស់នោះ ដោយបង្ហាញពីមូលដ្ឋានអោយបានច្បាស់លាស់ ។ ចំណែកអនុសាសន៍វិញ អ្នកសំរបសំរួលអាចដាក់ក្នុងការពិភាក្សា ជាមួយសិក្ខាកាម ឬ បើអាចឆ្លើយបានទៅនឹងអនុសាសន៍ទាំងនោះ អ្នកសំរបសំរួលអាចឆ្លើយតបបាន ។

*កំនត់ចំណាំ : រាល់សំនួរ និង អនុសាសន៍នានាដែលបានលើកឡើងដោយសិក្ខាកាមនៅក្នុងវគ្គនិមួយៗ មានសារៈសំខាន់ណាស់ ដែលអាចយកមកកែលំអមេរៀននិមួយ ៗ។ ដូច្នេះអ្នកសំរបសំរួលត្រូវកត់ត្រាទុកទាំងអស់ ហើយយកមកកែលំអមេរៀនអោយ បានល្អ និង សមស្រប ។*

១២. ការអនុវត្តសាកល្បងនេះ ត្រូវធ្វើផ្អែកលើពតិមានទាក់ទងនឹងមុខសញ្ញាគ្រោះថ្នាក់ ភាពងាយរងគ្រោះ ហានិយភ័យ សមត្ថភាព និង សេចក្តីត្រូវការជាក់ស្តែង ដើម្បីដោះស្រាយទៅនឹងមុខសញ្ញាគ្រោះថ្នាក់និមួយៗ ដែលពតិមានទាំងនេះត្រូវបានប្រមូលបានពីការចុះស្រង់ពតិមាន ឬ ពតិមានមានដែលមានស្រាប់របស់អាជ្ញាធរ និង សហគមន៍ ។

| | |
|---|---|
| **៦. ការអនុវត្តសាកល្បង ក្នុងការរៀបចំផែនការត្រៀមបង្ការគ្រោះមហន្តរាយ** | ១៣. ដើម្បីធ្វើលំហាត់នេះ ត្រូវបែងចែកសិក្ខាកាមជាក្រុមតូចៗទៅតាមចំនួននៃមុខសញ្ញាគ្រោះថ្នាក់សំខាន់ៗដែលបានកំនត់ (ទឹកជំនន់ ខ្យល់ព្យុះ រាំងស្ងួត សត្វល្អិតបំផ្លាញដំណាំ......) ។ ក្រុមនិមួយៗ ត្រូវរៀបចំផែនការតែលើមុខសញ្ញាគ្រោះថ្នាក់តែមួយគត់ ក្នុងចំណោមមុខសញ្ញាសំខាន់ៗដែលបានកំនត់ ***ឧទាហរណ៍*** ក្រុមដែលទទួលខុសត្រូវក្នុងការរៀបចំផែនការត្រៀមបង្ការគ្រោះទឹកជំនន់ ត្រូវកំនត់ និង វិភាគអោយបានល្អិតល្អន់លើពតិមានទាក់ទងនឹងមុខសញ្ញាគ្រោះថ្នាក់នេះ (ឧ. តើគ្រោះទឹកជំនន់បង្កបញ្ហាសំខាន់ៗអ្វីខ្លះ...? តើអ្វីខ្លះដែលជាភាពងាយរងគ្រោះដោយសារមុខសញ្ញាគ្រោះថ្នាក់នេះ? និង តើអ្វីខ្លះជាហានិយភ័យបណ្តាលមកពីមុខសញ្ញាគ្រោះថ្នាក់នេះ ..?. តើវិធានការសំខាន់ៗអ្វីខ្លះ ដែលអាចដោះស្រាយបញ្ហាទាំងអស់ខាងលើ...? ។ |
| | ១៤. ការបែងចែកសិក្ខាកាមដើម្បីធ្វើលំហាត់នេះ ត្រូវបែងចែកអោយមានសមាសភាពចំរុះមកពីគ្រប់ផ្នែកដែលពាក់ព័ន្ធ និង សមាសភាពអាជ្ញាធរ មកពីគ្រប់កំរិត អាជ្ញាធរឃុំ មន្ទីរពាក់ព័ន្ធថ្នាក់ខេត្ត និង ស្រុក និង ភូមិ (បើមាន...) ។ ផ្តល់ពេលវេលាអោយបានគ្រប់គ្រាន់ ដល់ក្រុមនិមួយៗ ក្នុងការភិភាក្សា និង រៀបចំផែនការនេះ (ពី ៣ — ៤ ម៉ោង យ៉ាងតិច) |
| | ១៥. ក្រោយពីក្រុមនិមួយៗបានពិភាក្សា និង បានរៀបចំពង្រាងនៃផែនការត្រៀមបង្កតាមមុខសញ្ញាគ្រោះថ្នាក់និមួយៗមក ក្រុមនិមួយត្រូវបង្ហាញពង្រាងរបស់ខ្លួនដល់ក្រុមធំ ។ នៅពេលនេះ ក្រុមដទៃ ដែលមិនបានចូលរួមពិភាក្សាលើមុខសញ្ញានេះ ត្រូវផ្តល់យោបល់.. ឬ ស្នើសុំបន្ថែមនូវរាល់វិធានការណាដែលបានទាន់បានបញ្ចូលនៅឡើយ ហើយដែលវិធានការនេះមានសារៈសំខាន់ ហើយវាទាក់ទងនឹងវិស័យណាមួយជាក់លាក់ ។ ការពិភាក្សាបែបនេះ ត្រូវធ្វើអោយបានគ្រប់ផែនការដែលទាក់ទងនឹងគ្រប់មុខសញ្ញាទាំងអស់ ដូច្នេះវាទាមទារពេលវេលាច្រើនក្នុងការពិភាក្សាលើពង្រាងនេះ ។ |
| | ១៦. នៅពេលដែលក្រុមនិមួយៗបង្ហាញនូវពង្រាងនេះផងដែរ គ្រូសម្របសម្របសំរួលត្រូវជួយផ្តល់យោបល់ និង បំផុសនូវគំនិតសំខាន់ៗមួយចំនួនដែលពាក់ព័ន្ធ ដែលមិនទាន់បានបញ្ចូលនៅក្នុងពង្រាងនៅឡើយៗ ជាពិសេស ត្រូវកត់ត្រានូវកង្វះខាតទាំងអស់ដែលត្រូវបំពេញបន្ថែមនៅគ្រប់ក្រុម ។ នៅចុងបញ្ចប់នៃការពិភាក្សានេះ គ្រូសម្របសម្រួលត្រូវលើកយកចំណុចដែលត្រូវបំពេញបន្ថែមមកផ្តល់យោបល់ដល់ក្រុមនិមួយៗ ។ |

# មេរៀនទី ៦.១: ប្រព័ន្ធផ្តល់ពត៌មានជាមុនពីគ្រោះទឹកជំនន់តាមសហគមន៍ (EWS)

## ១. ចំណុចសំខាន់ៗក្នុងមេរៀន

ក- និយមន័យ

ខ- បណ្តាញជាតិ សំរាប់ការព្យាករណ៍ និង ការផ្តល់ពិតមានជាមុន

គ- ដំណាក់កាលនៃការព្យាករណ៍ និង ការផ្តល់ពិតមានជាមុន

ឃ- កម្មវិធីផ្តល់ពិតមានជាមុនពីទឹកជំនន់តាមសហគមន៍

## ២. គោលបំណង

នៅចុងបញ្ចប់នៃមេរៀនសិក្ខាកាមទាំងអស់អាចមានលទ្ធភាព:

- បានស្គាល់ច្បាស់ពីប្រពន្ធ័ផ្តល់ពិតមានជាមុនដែលប្រើប្រាស់នៅតាមសហគមន៍
- យល់ដឹងពីសារៈប្រយោជន៍របស់វា
- ដឹងពីបណ្តាញសំរាប់ព្យាករណ៍ និង ប្រពន្ធ័ផ្តល់ពិតមានជាមុន
- អាចយកទៅអនុវត្តឱ្យមានប្រសិទ្ធិភាពនៅក្នុងសហគមន៍របស់ខ្លួន

## ៣. រយៈពេល: ០១ ម៉ោង និង ៣០នាទី

## ៤. សំភារៈឧបទេ្ទសន៍

- ក្តារខៀន
- ក្រដាសផ្ទាំងធំ
- ហ្វឺដសរសេរ (ចំរុះពិណ)
- ស្កុតបិទក្រដាស
- ឯកសារមេរៀន
- ឧបករណ៍ ឬ រូបភាពគំនូសក្រើតកំពស់ទឹក
- ម៉ាស៊ីនបញ្ចាំងស្លៃដ៏

## ៥. ដំណើរការ

**៣. បង្ហាញគោលបំណងមេរៀន និង លទ្ធផលរំពឹងទុកដល់ សិក្ខាកាម**

១. អ្នកសំរបសំរួលនឹងបង្ហាញគោលបំណងមេរៀន និង លទ្ធផលរំពឹងទុករបស់ខ្លួន ក្រោយពីបានបង្រៀនមេរៀននេះ។ អ្នកសំរបសំរួលអាចសរសេរគោលបំណង និង លទ្ធផលរំពឹងទុកនេះ លើក្ដារខៀន ឬ ក្រដាស់ផ្ទាំងធំ ឬ បញ្ចាំងស្លាយ ។

**៤. គំនិតទូទៅនៃត្រៀមបង្ការគ្រោះមហន្តរាយ**

២. មុនពេលចាប់ផ្ដើមសិក្សាពីមេរៀនទី ៥ នេះ អ្នកសំរបសំរួលត្រូវរិះរកវិធីសាស្រ្តដើម្បីទាញការយកចិត្តទុកដាក់របស់សិក្ខាកាមអោយផ្ដោតសំខាន់លើការត្រៀមបង្ការនៅមុនពេលមានគ្រោះមហន្តរាយកើតឡើង ធ្វើយ៉ាងណាអោយសិក្ខាកាមផ្សាភ្ជាប់នូវអ្វីដែលគេបានរៀនសូត្រពីពីមេរៀនទី ៣ និង មេរៀនទី ៤ ដោយលើកឡើងនូវចំណុចគន្លឹះសំខាន់ៗមកបញ្ជាក់ថា ការងារឆ្លើយតប សង្គ្រោះបន្ទាន់ និង ការស្ដារឡើងវិញ ឬ ជួសជុលឡើងវិញបានឆាប់រហ័ស និង មានប្រសិទ្ធិភាព ដរាបណាអាជ្ញាធរ និង សហគមន៍ដែលរស់នៅតំបន់ប្រឈមមុខនឹងគ្រោះមហន្តរាយមានកម្មវិធី ឬ ផែនការត្រៀមបង្ការមួយច្បាស់លាស់ជាមុន។ ព្រោះកម្មវិធី ឬ ផែនការត្រៀមបង្ការបានកំនត់ពីវិធានការណ៍ត្រូវធ្វើនៅមុនពេល កំឡុងពេល និង ក្រោយពេលមានគ្រោះមហន្តរាយ និង បានកំនត់ពីតួនាទី និង ការទទួលខុសត្រូវរបស់ស្ថាប័ន និង អ្នកពាក់ព័ន្ធរួចជាស្រេច ។ កម្មវិធី ឬ ផែនការអាចជួយពង្រឹងនូវកិច្ចសហប្រតិបត្តិការ និង ការសំរបសំរួល ជាពិសេសវាអាចជួយក្នុងការស្វែងរកធនធាន និង ការគាំទ្រផ្សេងៗ សំរាប់អនុវត្តនៅកំឡុងពេល និង ក្រោយពេលមានគ្រោះមហន្តរាយ ។

៣. ភ្ជាប់ទៅនឹងការទាញការចិត្តទុកដាក់នេះ អ្នកសំរបសំរួលអាចធ្វើបទបង្ហាញខ្លីពីគំនិតទូទៅ និង សារៈសំខាន់នៃការត្រៀមបង្ការគ្រោះមហន្តរាយជាមុន មុននឹងចូលដល់ខ្លឹមសារសំខាន់នៃកម្មវិធីត្រៀមបង្ការគ្រោះទឹកជំនន់ ដែលជាចំនុចគន្លឹះនៃមេរៀនទី ៥ នេះ ។

*កំនត់ចំណាំ : សូមមើលមេរៀនក្នុងផ្នែកទី៥ ទំព័រទី៤៩ និង បទបង្ហាញ លេខ....*

*គ. តើពត៌មានព្យាករណ៍ និង ពត៌មានប្រកាសភាពអាសន្នពីគ្រោះទឹកជំនន់ បានជួយអ្វីខ្លះ ដល់អាជ្ញាធរ និង ប្រជាជនដែលរស់នៅតំបន់ប្រឈមមុខនឹងគ្រោះភ័យ?*

៤. ក្រោយពីក្រុមនិមួយៗបានពិភាក្សារួចមក តំណាងក្រុមនិមួយៗត្រូវមកបង្ហាញលទ្ធផលនៃការពិភាក្សារបស់ខ្លួន។ កំនត់សំគាល់ អ្នកសំរបសំរួលនឹងកំនត់ពេលវេលាសមស្រប ដើម្បីអោយក្រុមនិមួយៗបង្ហាញលទ្ធផល និង ឆ្លើយសំនួរផ្សេងពីក្រុមធំ ។

**៤. ការពិភាក្សា និង សំនួរ-ចំលើយ**

៥. ក្រោយពីក្រុមនិមួយៗបានបង្ហាញលទ្ធផលរួចហើយ អ្នកសំរបសំរួលត្រូវសំរបសំរួលអោយមានការពិភាក្សា និង លើកជាសំនួរបញ្ជាក់ ឬ ផ្តល់ជាអនុសាសន៏ផ្សេងៗលើលទ្ធផលរបស់ក្រុមនិមួយ ៗ។

៦. បន្ទាប់មកពីការបង្ហាញលទ្ធផល និង ការពិភាក្សាក្រុមធំរួចមក អ្នកសំរបសំរួលត្រូវផ្តល់បទបង្ហាញទិដ្ឋភាពទូទៅ និង សារៈប្រយោជន៏នៃប្រព័ន្ធនេះ និង ផ្តល់បទបង្ហាញលំអិតបន្ថែមទៀតពីឧបករណ៍ វិធីសាស្រ្ត និង បណ្តាញជាតិសំរាប់ប្រើប្រាស់សំរាប់ផ្តល់ពតិមានព្យាករណ៍ និង ការផ្តល់ពតិមានជាមុន ដែលមានស្រាប់តាំងពីថ្នាក់ជាតិ រហូតដល់ថ្នាក់មូលដ្ឋាន។ ជាពិសេស លើកពីបទពិសោធន៏ និង មេរៀនល្អៗដែលទទួលបានពី ការអនុវត្តន៏សំដៅចែករំលែកដល់សិក្ខាកាម ។

៧. ជាចុងក្រោយ អ្នកសំរបសំរួលត្រូវផ្តល់ឱកាសអោយសិក្ខាកាមអាចលើកជាសំនួរ ដើម្បីអោយបញ្ជាក់អោយបានច្បាស់ និង សិក្ខាកាមអាចផ្តល់ជាអនុសាសន៏ទាក់ទងនឹងខ្លឹមសារមេរៀននេះ។

*កំនត់ចំណាំ : សូមមើលក្នុងផ្នែកទី៦ មេរៀនទី១ ទំព័រទី៦១ និង បទបង្ហាញ លេខ....*

៨. រាល់សំនួរ និង អនុសាសន៏នានាដែលបានសិក្ខាកាមបានលើកឡើង អ្នកសំរបសំរួលត្រូវសរសេរលើក្តារខៀន ឬ ក្រដាស់ផ្ទាំងធំ ។

៩. ក្រោយពីបានទទួលសំនួរ និង អនុសាសន៏ទាំងអស់ហើយ អ្នកសំរបសំរួលអាចចាប់ផ្តើមឆ្លើយទាំងអស់នោះ ដោយបង្ហាញពីមូលដ្ឋានអោយបានច្បាស់លាស់ ។ ចំណែក អនុសាសន៏វិញ អ្នកសំរបសំរួលអាចដាក់ក្នុងការពិភាក្សា ជាមួយសិក្ខាកាម ឬបើអាចឆ្លើយបានទៅនឹងអនុសាសន៏ ទាំងនោះ អ្នកសំរបសំរួលអាចឆ្លើយតបបាន។

*កំនត់ចំណាំ : រាល់សំនួរ និង អនុសាសន៏នានាដែលបានលើកឡើងដោយសិក្ខាកាមនៅក្នុងវគ្គនិមួយៗមានសារៈសំខាន់ណាស់ ដែលអាចយកមកកែលំអមេរៀននិមួយៗ។ ដូច្នេះ អ្នកសំរបសំរួលត្រូវកត់ត្រាទុកទាំងអស់ ហើយយកមកកែលំអមេរៀនអោយបានល្អ និង សមស្រប។*

# មេរៀនទី ៦.២: ការជម្លៀស និង ការគ្រប់គ្រងទីកន្លែងជម្លៀស

## ១. ចំណុចសំខាន់ៗក្នុងមេរៀន

ក- និយមន័យ

ខ- ចំណុចសំខាន់ៗដែលត្រូវយកចិត្តទុកដាក់នៅពេលជម្លៀស

គ- ការគ្រប់គ្រងទីកន្លែងជម្លៀស

ឃ- មុខងារ និងការទទួលខុសត្រូវរបស់ក្រុម/គណៈកម្មការនានា

## ២. គោលបំណង

នៅចុងបញ្ចប់នៃមេរៀន សិក្ខាកាមទាំងអស់នឹងយល់ដឹងពីៈ

- ការជន្លៀស និងការគ្រប់គ្រងទីកន្លែងជម្លៀស
- អាចរៀបចំចាត់ចែង និងបង្កើតជាក្រុម/គណៈកម្មការនានានៅតាមសហគមន៍របស់ខ្លួន ដោយភ្ជាប់ជាមួយតួនាទី និងការទទួលខុសត្រូវរបស់ក្រុមនីមួយៗ

## ៣. រយៈពេល: ០១ ម៉ោង និង ៥០នាទី

## ៤. សំភារៈឧបទេ្ទសន៍

- ក្តារខៀន
- ក្រដាសផ្ទាំងធំ
- ហ្វឺដសរសេរ (ចំរុះពណ៌)
- ស្កុតបិទក្រដាស
- ឯកសារមេរៀន
- ម៉ាស៊ីនបញ្ចាំងស្លែដ៏

## ៥. ដំណើរការ

**១. បង្ហាញគោលបំណងមេរៀន និង លទ្ធផលរំពឹងទុកដល់សិក្ខាកាម**

១. អ្នកសំរបសំរួលនឹងបង្ហាញគោលបំណងមេរៀន និង លទ្ធផលរំពឹងទុករបស់ខ្លួន ក្រោយពីបានបង្រៀនមេរៀននេះ។ អ្នកសំរបសំរួលអាចសរសេរគោលបំណង និង លទ្ធផលរំពឹងទុកនេះ លើក្តារខៀន ឬ ក្រដាស់ផ្ទាំងធំ ឬ បញ្ចាំងស្លាយ ។

**២. និយមន័យ**

២. ជាកិច្ចចាប់ផ្តើមនៃការសំរបសំរួលលើមេរៀននេះ អ្នកសំរបសំរួលត្រូវលើកជាសំនួរបំផុសដើម្បីអោយសិក្ខាកាមចូលរួមកំនត់ពី និយមន័យ "***ការជំលៀស***" អ្នកសំរបសំរួលអាចប្រើសំនួរងាយៗ ដូចជា តើការជំលៀសជាអ្វី? *និង* អ្វីខ្លះដែលត្រូវជំលៀស? ។

**៣. យន្តការក្នុងការជំលៀសប្រកបដោយប្រសិទ្ធិភាព**

៣. នៅពេលដែលសិក្ខាកាមចូលរួមកំនត់និយមន័យ អ្នកសំរបសំរួលត្រូវកត់ត្រាចំលើយទាំងអស់ដាក់លើក្តារខៀន ឬ ក្រដាសផ្ទាំងធំ។ បន្ទាប់មក អ្នកសំរបសំរួលត្រូវបូកសរុបចំលើយទាំងនេះ ព្រមទាំងធ្វើបទបង្ហាញ ដោយលើកយកនិយមន័យពិតប្រាកដ ដើម្បីចែករំលែកជូនសិក្ខាកាម ។

**៤. ការគ្រប់គ្រងទីកន្លែងជំលៀស**

**៥. ចំណុចសំខាន់ៗដែលត្រូវយកចិត្តទុកដាក់ក្នុងការជំលៀស**

៤. ដើម្បីសិក្សាស្វែងយល់ និង ទទួលបានបទពិសោធន៍ ពីការអនុវត្តន៍ជាក់ស្តែងរបស់សិក្ខាកាមលើយន្តការ និង របៀបដែលគេធ្លាប់អនុវត្តកន្លងមកលើការជំលៀស និង ការគ្រប់គ្រងទីកន្លែងជំលៀស អ្នកសំរបសំរួលត្រូវបែងចែកសិក្ខាកាមជា ២ ឬ ៣ ក្រុមតូចៗ ដើម្បីពិភាក្សាលើសំនួរដូចតទៅ :

**១. ទិដ្ឋភាពទូទៅនៃប្រព័ន្ធផ្តល់ពត៌មានជាមុន រួមមាន (ឧបករណ៍ វិធីសាស្ត្រ បណ្តាញជាតិ និង តំរោងនានា**

*ក. តើយន្តការអ្វីខ្លះដែលអាជ្ញាធរ និង អ្នកទទួលរងគ្រោះធ្លាប់បានប្រើប្រាស់ក្នុងការជំលៀស អោយមានប្រសិទ្ធិភាព?*

*ខ. តើពត៌មានជាមូលដ្ឋានអ្វី ដើម្បីសំរេចចិត្តក្នុងការជំលៀស? តើអ្នកណាដែលជាអ្នកសំរេចចិត្ត ?*

*គ. តើធ្វើដូចម្តេច ដើម្បីគ្រប់គ្រងទីកន្លែងជំលៀស និង ប្រជាជនដែលជំលៀសមកស្នាក់នៅបណ្តោះអាសន្ន (សន្តិសុខ ជម្លោះ ជំរក ទឹកស្អាត បង្គន់...)?*

## ៦. ការពិភាក្សា និង សំនួរ-ចំលើយ

៥ ក្រោយបានពិភាក្សា តំណាងក្រុមនិមួយៗ ត្រូវបង្ហាញពីលទ្ធផលនៃការពិភាក្សាដល់នៅក្នុងក្រុមធំ ។ នៅពេលក្រុមនិមួយៗបង្ហាញលទ្ធផល សមាជិកនៃក្រុមដទៃអាចលើកជាសំនួរបញ្ជាក់ ឬ អនុសាសន៍បំពេញបន្ថែម ។

៦ បន្ទាប់មកពីការបង្ហាញលទ្ធផល និង ការពិភាក្សាក្រុមធំរួចមក អ្នកសំរបសំរួលត្រូវផ្តល់បទបង្ហាញពីយន្តការ និង បទពិសោធន៍ពីការជំលៀស និង ការគ្រប់ទីកន្លែងជំលៀ ។ ជាពិសេស លើកពីបទពិសោធន៍ និង មេរៀនល្អៗដែលទទួលបានពីការអនុវត្តន៍ សំដៅចែករំលែកដល់សិក្ខាកាម ។

៧ ជាចុងក្រោយ អ្នកសំរបសំរួលត្រូវផ្តល់ឱកាសអោយសិក្ខាកាមអាចលើកជាសំនួរ ដើម្បីអោយបញ្ជាក់អោយបានច្បាស់ និង សិក្ខាកាមអាចផ្តល់ជាអនុសាសន៍ទាក់ទងនឹងខ្លឹមសារមេរៀននេះ ។

៨ រាល់សំនួរ និង អនុសាសន៍នានាដែលបានសិក្ខាកាមបានលើកឡើង អ្នកសំរបសំរួលត្រូវសរសេរលើក្តារខៀន ឬ ក្រដាស់ផ្ទាំងធំ ។

៩ ក្រោយពីបានទទួលសំនួរ និង អនុសាសន៍ទាំងអស់ហើយ អ្នកសំរបសំរួលអាចចាប់ផ្តើមឆ្លើយទាំងអស់នោះ ដោយបង្ហាញពីមូលដ្ឋានអោយបានច្បាស់លាស់ ។ ចំណែកអនុសាសន៍វិញ អ្នកសំរបសំរួលអាចដាក់ក្នុងការពិភាក្សា ជាមួយសិក្ខាកាម ឬ បើអាចឆ្លើយបានទៅនឹងអនុសាសន៍ទាំងនោះ អ្នកសំរបសំរួលអាចឆ្លើយតបបាន ។

*កំនត់ចំណាំ : រាល់សំនួរ និង អនុសាសន៍នានាដែលបានលើកឡើងដោយសិក្ខាកាមនៅក្នុងវគ្គនិមួយៗ មានសារៈសំខាន់ណាស់ ដែលអាចយកមកកែលំអមេរៀននិមួយ ៗ ។ ដូច្នេះអ្នកសំរបសំរួលត្រូវកត់ត្រាទុកទាំងអស់ ហើយយកមកកែលំអមេរៀនអោយ បានល្អ និង សមស្រប ។*

# មេរៀនទី ៦.៣: ការគ្រប់គ្រងសុខភាពសាធារណៈ ក្នុងរដូវទឹកជំនន់

## ១. ចំណុចសំខាន់ៗក្នុងមេរៀន

ក- និយមន័យ

ខ- វិធានការណ៍សំខាន់ៗសំរាប់ត្រៀមបង្ការ និងកាត់បន្ថយគ្រោះថ្នាក់

គ- វិធីបង្ការជំងឺឆ្លងផ្សេងៗ និង ជំងឺកង្វះអាហារូបត្ថម្ភ

ឃ- វិធីបង្ការជំងឺលើទារក (ក្រោមអាយុ ១៨ឆ្នាំ) នាពេលទឹកជំនន់

ង- ការត្រៀមសំភារៈប្រើប្រាស់ និងស្បៀងអាហារផ្សេងៗ

ច- របៀបថែរក្សាទឹកស្អាតសំរាប់បរិភោគ

ឆ- បទដ្ឋានសំខាន់ៗដែលត្រូវគិតគូរសំរាប់បំរើឱ្យស្ថានភាពសុខភាព និងជីវភាពរស់នៅរបស់សហគមន៍ក្នុងពេលទឹកជំនន់

## ២. គោលបំណង

នៅចុងបញ្ចប់នៃមេរៀន សិក្ខាកាមទាំងអស់នឹងយល់ដឹងពីៈ

- វិធានការត្រៀមបង្ការសំខាន់ៗទាក់ទងសុខភាពសាធារណៈ សំរាប់អនុវត្តនារដូវទឹកជំនន់ ដូចជាៈ វិធីបង្ការជំងឺឆ្លង និងជំងឺកង្វះអាហារូបត្ថម្ភ, វិធីបង្ការទារកអាយុក្រោម០៥ឆ្នាំ, ការត្រៀមសំភារៈនិងស្បៀងអាហារ, របៀបថែរក្សាទឹកស្អាតសំរាប់បរិភោគ និង បទដ្ឋានផ្សេងៗ ជាដើម ។

## ៣. រយៈពេលៈ ០២ ម៉ោង និង ៣០នាទី

## ៤. សំភារៈឧបទេ្ទសន៍

- ក្ដារខៀន
- ក្រដាសផ្ទាំងធំ
- ហ្វឺដសរសេរ (ចំរុះពណ៌)
- ស្កុតបិទក្រដាស
- ឯកសារមេរៀន
- ម៉ាស៊ីនបញ្ចាំងស្លែដ៏

## ៥. ដំណើរការ

**១. បង្ហាញគោលបំណងមេរៀន និង លទ្ធផលរំពឹងទុកដល់សិក្ខាកាម**

**២. និយមន័យ**

**៣. វិធានការណ៍សំខាន់ៗសំរាប់ត្រៀមបង្ការ និងកាត់បន្ថយគ្រោះថ្នាក់**

**៤. វិធីបង្ការជំងឺឆ្លងផ្សេងៗ និង ជំងឺកង្វះអាហារូបត្ថម្ភ**

**៥. វិធីបង្ការជំងឺលើទារក (ក្រោមអាយុ ០៥ឆ្នាំ) នាពេលទឹកជំនន់**

**៦. ការត្រៀមសំភារៈប្រើប្រាស់ និងស្បៀងអាហារផ្សេងៗ**

**៧. របៀបថែរក្សាទឹកស្អាតសំរាប់បរិភោគ**

**៨. បទដ្ឋានសំខាន់ៗដែលត្រូវគិតគូរសំរាប់បំរើឱ្យស្ថានភាពសុខភាព និងជីវភាពរស់នៅរបស់សហគមន៍ក្នុងពេលទឹកជំនន់**

១. អ្នកសំរបសំរួលនឹងបង្ហាញគោលបំណងមេរៀន និង លទ្ធផលរំពឹងទុករបស់ខ្លួន ក្រោយពីបានបង្រៀនមេរៀននេះ។ អ្នកសំរបសំរួលអាចសរសេរគោលបំណង និង លទ្ធផលរំពឹងទុកនេះ លើក្តារខៀន ឬ ក្រដាស់ផ្ទាំងធំ ឬ បញ្ចាំងស្លាយ ។

២. ជាកិច្ចចាប់ផ្តើមនៃការសំរបសំរួលលើមេរៀននេះ អ្នកសំរបសំរួលត្រូវលើកជាសំនួរ បំផុសដើម្បីអោយសិក្ខាកាមចូលរួមកំណត់ពីនិយមន័យ "***អ្វីជាសុខភាពសាធារណៈ?***" .

៣. នៅពេលដែលសិក្ខាកាមចូលរួមកំណត់និយមន័យ អ្នកសំរបសំរួលត្រូវកត់ត្រាចំលើយទាំងអស់ដាក់លើក្តារខៀន ឬ ក្រដាសផ្ទាំងធំ។ បន្ទាប់មក អ្នកសំរបសំរួលត្រូវបូកសរុបចំលើយទាំងនេះ ព្រមទាំងធ្វើបទបង្ហាញ ដោយលើកយកនិយមន័យពិតប្រាកដ ដើម្បីចែករំលែកជូនសិក្ខាកាម។

៤. ដើម្បីបង្កើការយល់ដឹងបន្ថែមទៀត អ្នកសំរបសំរួល ត្រូវបំផុសឡើងនូវសំណួរទាក់ទិននឹងការចូលរួម និងការប្រើប្រាស់តួនាទីរបស់សហគមន៍ លើផ្នែកសុខភាពសាធារណៈ ដោយប្រើប្រាស់សំណួរ ខាងក្រោម:

*ក- តើសុខភាពសាធារណៈជាកិច្ចការងាររបស់អ្នកណា?*

*ខ- ហេតុអ្វីបានជាចាំបាច់ត្រូវអប់រំពីសុខភាពសាធារណៈនារដូវទឹកជំនន់?*

*គ- តើនរណាខ្លះអាចធ្វើការងារអប់រំសុខភាពសាធារណៈបាន?*

១. បន្ទាប់មក, អ្នកសំរបសំរួល ត្រូវកត់ត្រារាល់ចំលើយដែលមានលក្ខណៈសមស្របអាចទទួលយកបានដាក់លើក្តារ ខៀន ឬក្រដាសផ្ទាំងធំរួចធ្វើការសំយោគខ្លឹមសាររួមមួយផ្តល់ជូនទៅសិក្ខាកាមវិញ។

២. រីឯចំណុចខ្លឹមសារដទៃទៀតក្នុងមេរៀននេះ អ្នកសំរបសំរួលក៏ត្រូវអនុវត្តដូចការណែនាំខាងលើនេះដែរ ជាមួយនឹងបទបង្ហាញដែលបានបញ្ចាំងនៅលើផ្ទាំងសំពត់។

*កំនត់ចំណាំ : សូមមើលផ្នែកទី៦ មេរៀនទី៥ ទំព័រទី៨០ និង បទបង្ហាញ លេខ....*

# មេរៀនទី ៦.៤: ការគ្រប់គ្រងបញ្ជីធនធាន សំរាប់ត្រៀមបង្ការនិងកាត់បន្ថយគ្រោះទឹកជំនន់

## ១. ចំណុចសំខាន់ៗក្នុងមេរៀន

ក- សារៈសំខាន់នៃការគ្រប់គ្រងធនធាន និង ប្រើប្រាស់ធនធាន

ខ- ប្រភពធនធាន ( គ្រួសារ, សហគមន៍, ភូមិ-ឃុំ-ស្រុក-ខេត្ត, និង ជាតិ)

## ២. គោលបំណង

នៅចុងបញ្ចប់នៃមេរៀន សិក្ខាកាមទាំងអស់នឹងអាចៈ

- យល់ដឹងពីប្រភេទធនធាន និងសំភារៈតម្រូវការរបស់សហគមន៍ ដើម្បីត្រៀមឆ្លើយតបនឹងគ្រោះទឹកជំនន់
- មានលទ្ធភាពក្នុងការកៀងគរនូវធនធានដែលត្រូវការ សំរាប់ត្រៀមឆ្លើយតបចំពោះគ្រោះទឹកជំនន់
- ស្វែងយល់ពីប្រភពធនធានតម្រូវការផ្សេងៗទៀតពីប្រភពខាងក្រៅ

## ៣. រយៈពេលៈ ០១ ម៉ោង និង ៣០នាទី

## ៤. សំភារៈឧបទេ្ទសន៍

- ក្តារខៀន
- ក្រដាសផ្ទាំងធំ
- ហ្វឺដសរសេរ ( ចំរុះពិណ)
- ស្កុតបិទក្រដាស
- ឯកសារមេរៀន
- រូបភាពផ្សព្វផ្សាយ/អប់រំផ្សេងៗ
- ម៉ាស៊ីនបញ្ចាំងស្លែដ៏

## ៤. ដំណើរការ

**១. សារៈសំខាន់នៃការគ្រប់គ្រងធនធាន និងប្រើប្រាស់ធនធាន**

១. អ្នកសំរបសំរួលនឹងបង្ហាញគោលបំណងមេរៀន និង លទ្ធផលរំពឹងទុករបស់ខ្លួន ក្រោយពីបានបង្រៀនមេរៀននេះ។ អ្នកសំរបសំរួលអាចសរសេរគោលបំណង និង លទ្ធផលរំពឹងទុកនេះ លើក្តារខៀន ឬ ក្រដាស់ផ្ទាំងធំ ឬ បញ្ចាំងស្លាយ ។

១. ជាកិច្ចចាប់ផ្តើមនៃការសំរបសំរួលលើមេរៀននេះ អ្នកសំរបសំរួលត្រូវលើកជាសំនួរបំផុសដើម្បីអោយសិក្ខាកាមចូលរួមកំណត់ពីនិយមន័យ " ***អ្វីទៅជាធនធាន?*** ", និងតើធនធានមានអ្វីខ្លះ?

២. នៅពេលដែលសិក្ខាកាមចូលរួមកំណត់និយមន័យ អ្នកសំរបសំរួលត្រូវកត់ត្រាចំលើយទាំងអស់ដាក់លើក្តារខៀន ឬ ក្រដាសផ្ទាំងធំ។ បន្ទាប់មក អ្នកសំរបសំរួលត្រូវបូកសរុបចំលើយទាំងនេះ ព្រមទាំងធ្វើបទបង្ហាញ ដោយលើកយកនិយមន័យពិតប្រាកដ ដើម្បីចែករំលែកជូនសិក្ខាកាម។

៣. ដើម្បីបង្កើការយល់ដឹងបន្ថែមទៀត អ្នកសំរបសំរួល ត្រូវបំផុសឡើងនូវសំណួរផ្សេងៗទាក់ទិនការគ្រប់គ្រងនិងប្រើប្រាស់ធនធានដែលមាននៅក្នុងសហគមន៏ សំរាប់ធ្វើការត្រៀមបង្ការគ្រោះទឹកជំនន់ ដូចខាងក្រោម:

*ក. តើនៅក្នុងសហគមន៏របស់អ្នកមានធនធានអ្វីខ្លះ?*

**២- ប្រភពធនធាន (គ្រួសារ, សហគមន៏, ភូមិ-ឃុំ-ស្រុក-ខេត្ត, និង ជាតិ)**

*ខ. តើធនធានទាំងអស់ខាងលើ មានចុះក្នុងបញ្ជីសារពើភណ្ឌ័ហើយឬនៅ?*

*គ. តើធនធានដែលមាននៅក្នុងសហគមន៏របស់អ្នក អាចគ្រប់គ្រាន់សំរាប់បំរើឱ្យការងារគ្រប់គ្រងនិងត្រៀមបង្ការទឹកជំនន់ហើយឬនៅ?*

*ឃ. ឆ្លងតាមបទពិសោធន៏កន្លងមក តើអ្នកធ្លាប់បានចាត់ចែងនិងប្រើប្រាស់ធនធានដែលមានស្រាប់ សំរាប់ការងារគ្រប់គ្រង និងឆ្លើយតប នារដូវទឹកជំនន់យ៉ាងដូចម្តេចខ្លះ?*

*ង. តើអ្នកអាចស្វែងរកជំនួយធនធានបន្ថែមពីខាងក្រៅតាមប្រភពណាខ្លះ?*

៤. បន្ទាប់មក, អ្នកសំរបសំរួល ត្រូវកត់ត្រារាល់ចំលើយដែលមានលក្ខណៈសមស្របអាចទទួលយកបានដាក់លើក្តារខៀន ឬក្រដាសផ្ទាំងធំ រួចធ្វើការសំយោគខ្លឹមសារ រួមមួយផ្តល់អោយសិក្ខាកាមវិញ។

**១. សារៈសំខាន់នៃការគ្រប់គ្រងធនធាន និងប្រើប្រាស់ធនធាន**

**២- ប្រភពធនធាន (គ្រួសារ, សហគមន៍, ភូមិ-ឃុំ-ស្រុក-ខេត្ត, និង ជាតិ)**

៦. ក្រោយពីបានបំផុសសំណួរ និងមានការចូលរួមមតិយោបល់ ក៏ដូចជាបានយល់ដឹងខ្លះពីខ្លឹមសារសំខាន់ៗរបស់មេរៀនហើយនោះ, អ្នកសំរបសំរួល ត្រូវបង្ហាញពីខ្លឹមសារមេរៀនទាំងស្រុង នៅលើផ្ទាំងសំពត់ ជូនសិក្ខាកាមផ្ទៀងផាត់នូវចំលើយរបស់ពួកគេ និងទទួលបានចំណេះដឹងបំពេញបន្ថែម ។

*កំនត់ចំណាំ : សូមមើលផ្នែកទី៦ មេរៀនទី៦.៤ ទំព័រទី៧៤ និង បទបង្ហាញ លេខ....*

# មេរៀនទី ៧: ការធ្វើសមាហរណកម្ម កម្មវិធីត្រៀមបង្ការគ្រោះទឹកជំនន់ទៅក្នុងផែនការអភិវឌ្ឍន៍មូលដ្ឋាន

## ១. ចំណុចសំខាន់ៗក្នុងមេរៀន

១- តើអ្វីទៅជាផែនការអភិវឌ្ឍន៍ឃុំ/សង្កាត់ និង ផែនការវិនិយោគឃុំ/សង្កាត់?

*ក. និយមន័យ.*

*ខ. ទិដ្ឋភាពរួម*

*គ. គោលបំណង*

*ឃ. គោលគំនិតសំខាន់ៗ*

*ង. ការធ្វើសមាហរណកម្ម លើវិស័យអាទិភាពទាំង០៥របស់ឃុំ/សង្កាត់ ទៅក្នុងការងារគ្រប់គ្រងគ្រោះមហន្តរាយ*

*ច. ការងារគ្រប់គ្រងគ្រោះមហន្តរាយ*

២- តារាងម៉ាទ្រិច ស្តីពីគំរោងវិនិយោគឃុំទាក់ទងនឹងការកាត់បន្ថយគ្រោះទឹកជំនន់ ក្នុងឆ្នាំ២០០៨

៣- អនុសាសន៍ផ្សេងៗលើការធ្វើសមាហរណកម្ម នៃកម្មវិធីត្រៀមបង្ការគ្រោះទឹកជំនន់ ទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ និង ផែនការវិនិយោគឃុំ

## ២. គោលបំណង

នៅចុងបញ្ចប់មេរៀន សិក្ខាកាមទាំងអស់នឹងបានយល់ដឹងពីៈ

- និយមន័យនៃភាពខុសប្លែកគ្នារវាង ផែនការអភិវឌ្ឍន៍ឃុំ/សង្កាត់ និង ផែនការវិនិយោគឃុំ/សង្កាត់?
- ភាពទំនាក់ទំនងគ្នារវាង ការអភិវឌ្ឍន៍ និង ការគ្រប់គ្រងគ្រោះមហន្តរាយ ។
- ការកំណត់ពីរបៀបធ្វើសមាហរណកម្ម នៃកម្មវិធីត្រៀមបង្ការគ្រោះទឹកជំនន់ ទៅក្នុងផែនការអភិវឌ្ឍន៍ និង ផែនការវិនិយោគឃុំ ។
- អាចធ្វើសមាហរណកម្ម នៃកម្មវិធីត្រៀមបង្ការគ្រោះទឹកជំនន់ ទៅក្នុងវិស័យអាទិភាពសំខាន់ៗទាំង០៥ របស់ឃុំ ។

## ៣. រយៈពេលៈ ០២ ម៉ោង

## ៤. សំភារៈឧបទេ្ទសសន៍

- ក្តារខៀន
- ក្រដាសផ្ទាំងធំ

- ហ្វឺដសរសេរ ( ចំរុះពណ៌ )
- ស្កុតបិទក្រដាស
- ឯកសារមេរៀន
- ម៉ាស៊ីនបញ្ចាំងស្លៃដ៍

## ៥. ដំណើរការ

**១. តើអ្វីទៅជាផែនការ ? តើអភិវឌ្ឍន៍ឃុំ/សង្កាត់ និង ផែនការវិនិយោគឃុំ/សង្កាត់ មានលក្ខណៈខុសគ្នា ដូចម្តេច?**

៣. អ្នកសំរបសំរួលនឹងបង្ហាញគោលបំណងមេរៀន និង លទ្ធផលរំពឹងទុករបស់ខ្លួន ក្រោយពីបានបង្រៀនមេរៀននេះ ។ អ្នកសំរបសំរួលអាចសរសេរគោលបំណង និង លទ្ធផលរំពឹងទុកនេះ លើក្តារខៀន ឬ ក្រដាស់ផ្ទាំងធំ ឬ បញ្ចាំងស្លាយ ។

៤. ជាកិច្ចចាប់ផ្តើមនៃការសំរបសំរួលលើមេរៀននេះ អ្នកសំរបសំរួលត្រូវលើកជាសំនួរបំផុស ដើម្បីអោយសិក្ខាកាមចូលរួមកំណត់ពីនិយមន័យ "***អ្វីជាផែនការ?***"

៥. នៅពេលដែលសិក្ខាកាមចូលរួមកំណត់និយមន័យ អ្នកសំរបសំរួលត្រូវកត់ត្រាចំលើយទាំងអស់ដាក់លើក្តារខៀន ឬក្រដាសផ្ទាំងធំ ។ បន្ទាប់មក អ្នកសំរបសំរួល ត្រូវធ្វើការបូកសរុបចំលើយទាំងនេះ ព្រមទាំងធ្វើបទបង្ហាញ ដោយលើកយកនិយមន័យពិតប្រាកដ ដើម្បីចែករំលែកជូនសិក្ខាកាម ។

៦. ដើម្បីបង្កើការយល់ដឹងបន្ថែមដល់សិក្ខាកាម អ្នកសំរបសំរួល ត្រូវបំផុសនូវសំណួរ និង កត់ត្រាចំលើយរបស់សិក្ខាកាមដាក់លើក្តារខៀន ឬក្រដាសផ្ទាំងធំ ទាក់ទងនឹងនិយមន័យនៃប្រភេទផែនការនីមួយៗ ក៏ដូចជាភាពខុសប្លែកគ្នារបស់វា ដែលឃុំ/សង្កាត់នៅទូទាំងប្រទេសកំពុងអនុវត្តនាពេលបច្ចុប្បន្ននេះ នូវសំណួរដូចខាងក្រោមៈ

*ក- តើអ្វីជាផែនការអភិវឌ្ឍន៍ឃុំ/សង្កាត់?*

*ខ- អ្វីទៅជាផែនការវិនិយោគឃុំ/សង្កាត់?*

*គ- តើវិស័យអាទិភាពទាំង០៥របស់ឃុំ/សង្កាត់ មានអ្វីខ្លះ?*

*ឃ- តើដំណើរការកសាងផែនការឃុំ ចែកចេញជាប៉ុន្មានដំណាក់កាល? អ្វីខ្លះ?*

៥. បន្ទាប់ពីបានកត់ត្រាចំលើយចូលរួមរបស់សិក្ខាកាមរួចហើយ អ្នកសំរបសំរួល ត្រូវធ្វើការបូកសរុបចំលើយសមរម្យមួយ ដើម្បីផ្តល់ជូនទៅសិក្ខាកាមវិញ និង ផ្ទៀងផ្ទាត់ចំលើយត្រឹមត្រូវនៅលើស្លៃដ៏មេរៀន ដែលបានបញ្ចាំងនៅលើផ្ទាំងសំពត់ ។

**២. ការធ្វើសមាហរណកម្មលើវិស័យអាទិភាពទាំង០៥ របស់ឃុំ/សង្កាត់ ទៅក្នុងការងារគ្រប់គ្រងគ្រោះមហន្តរាយ**

៦. អ្នកសំរបសំរួល ត្រូវធ្វើការពន្យល់បន្ថែមឱ្យបានក្បោះក្បាយលើចំណុចសំខាន់នានា នៅក្នុងមេរៀនដែលបានបង្ហាញនៅលើផ្ទាំងសំពត់ ទាក់ទិននឹងស្ថានភាពហេដ្ឋារចនាសម្ព័ន្ធ , សិប្បកម្ម សេវាកម្ម ការងារអប់រំ ការងារសុខភាព/អនាម័យ ការប្រែប្រួលអាកាសធាតុ ការងារចុះអត្រានុកូលដ្ឋាន ការងារសណ្តាប់ធ្នាប់ សន្តិសុខមូលដ្ឋាន ការងារអំពើហឹង្សាក្នុងគ្រួសារ, ការងារពង្រឹងសមត្ថភាពនិងបណ្តុះបណ្តាល....ជាដើម ដែលទាក់ទិននឹងការងារគ្រប់គ្រងគ្រោះមហន្តរាយទៅក្នុងវិស័យអាទិភាពទាំង០៥ របស់ឃុំ/សង្កាត់ ។

**៣. ការងារគ្រប់គ្រងគ្រោះមហន្តរាយ**

៧. ក្នុងចំណុចនៃខ្លឹមសារនេះដែរ អ្នកសំរបសំរួល ក៏ត្រូវធ្វើការបកស្រាយនិងពន្យល់ផ្អែកលើមេរៀនដែលកំពុងបញ្ចាំងស្លៃដ៏នៅលើផ្ទាំងសំពត់ អំពីវិធានការអ្វីខ្លះដែលជាបច្ច័យមិនអាចខ្វះបាន សំរាប់បំរើឱ្យការងារគ្រប់គ្រងគ្រោះមហន្តរាយ ដូចជា:

- *វិធានការត្រៀមបង្ការបែបមិនមែន ហេដ្ឋារចនាសម្ព័ន្ធ (អរូបវន្ត)*
- *វិធានការត្រៀមបង្ការបែបហេដ្ឋារចនាសម្ព័ន្ធ (រូបវន្ត)*
- *វិធានការ សំរាប់បំរើឱ្យ ការជំលៀស សង្គ្រោះនិងឆ្លើយតប*
- *ការស្តារ និង ជួសជុលឡើងវិញ*

**៤. តារាងម៉ាទ្រិច ស្តីពីគំរោងវិនិយោគឃុំទាក់ទងនឹងការកាត់បន្ថយគ្រោះទឹកជំនន់ ក្នុងឆ្នាំ២០០៨**

៨. អ្នកសំរបសំរួល ត្រូវបញ្ចាំងស្លៃដ៏ដោយលើកយកតារាងម៉ាទ្រិចគំរូ នៃផែនការសកម្មភាពទាក់ទិនគំរោងកាត់បន្ថយគ្រោះទឹកជំនន់ ដែលឃុំ/សង្កាត់បានស្នើឡើងនិងបានដាក់បញ្ចូលទៅក្នុងផែនការវិនិយោគឆ្នាំ២០០៨ របស់ពួកគេ (ធ្វើជាឧទាហរណ៍) ។ បន្ទាប់មក អ្នកសំរបសំរួល ត្រូវអានផែនការសកម្មភាពទាំងនោះយ៉ាងតិចឱ្យបាន ៣ ទៅ ៤ ឈ្មោះគំរោងដែលមានគោលបំណងផ្សេងគ្នា ជូនសិក្ខាកាមបានសិក្សាស្វែងយល់ ។ ចំណុចខ្លឹមសារនេះក៏អាចជួយបំពេញចំណេះដឹងបន្ថែមដល់សិក្ខាកាម ដែលមិនទាន់យល់ដឹងស៊ីជំរៅពីខ្លឹមសារក្នុងមេរៀនដែលបានបង្ហាញរួចមកហើយ ក្នុងចំណុច (**២**) ផងដែរ ។

**៥. អនុសាសន៍ផ្សេងៗ លើការធ្វើសមាហរណកម្ម នៃកម្មវិធីត្រៀមបង្ការគ្រោះទឹកជំនន់ ទៅក្នុងផែនការ អភិវឌ្ឍន៍ និង ផែនការ វិនិយោគឃុំ/សង្កាត?**

**- សំណួរ និង ក្រុមពិភាក្សា**

៩. អ្នកសំរបសំរួល ត្រូវបែងចែកសិក្ខាកាមជា ០២-០៣ក្រុម ដើម្បីធ្វើការពិភាក្សាគ្នាលើប្រធានបទមួយរួមគ្នា ដូចខាងក្រោម៖

- *តើធ្វើដូចម្តេច ដើម្បីឱ្យការបញ្ចូលកម្មវិធីត្រៀមបង្ការគ្រោះទឹកជំនន់ទៅក្នុងផែនការអភិវឌ្ឍន៍ និងផែនការវិនិយោគឃុំ/សង្កាត់ មានប្រសិទ្ធិភាព និង ការអនុវត្តប្រកបដោយនិរន្តភាព?*

១០. ក្រោយពីបានពិភាក្សា តំណាងក្រុមនិមួយៗ ត្រូវបង្ហាញពីលទ្ធផលនៃការពិភាក្សាដល់នៅក្នុងក្រុមធំ។ នៅពេលក្រុមនិមួយៗបង្ហាញលទ្ធផល សមាជិកនៃក្រុមដទៃអាចលើកជាសំនួរបញ្ជាក់ ឬ អនុសាសន៍បំពេញបន្ថែម។

១០ .បន្ទាប់មកពីការបង្ហាញលទ្ធផល និង ការពិភាក្សាក្រុមធំរួចមក អ្នកសំរបសំរួលត្រូវផ្តល់បទបង្ហាញពីអនុសាសន៍ផ្សេងៗ និងបទពិសោធន៍នៃការអនុវត្តកន្លងមក សំរាប់ចែករំលែកដល់សិក្ខាកាម ។

១១. ជាចុងក្រោយ អ្នកសំរបសំរួល ត្រូវផ្តល់ឱកាសអោយសិក្ខាកាមអាចលើកជាសំនួរ ដើម្បីអោយបញ្ជាក់អោយបានច្បាស់ និង សិក្ខាកាមអាចផ្តល់ជាអនុសាសន៍ទាក់ទងនឹងខ្លឹមសារមេរៀននេះ។

១២. រាល់សំនួរ និង អនុសាសន៍នានាដែលបានសិក្ខាកាមបានលើកឡើង អ្នកសំរបសំរួលត្រូវសរសេរលើក្តារខៀន ឬ ក្រដាស់ផ្ទាំងធំ ។

១៣. ក្រោយពីបានទទួលសំនួរ និងអនុសាសន៍ទាំងអស់ហើយ អ្នកសំរបសំរួលអាចចាប់ផ្តើមឆ្លើយទាំងអស់នោះ ដោយបង្ហាញពីមូលដ្ឋានអោយបានច្បាស់លាស់ ។ ចំណែកអនុសាសន៍វិញ អ្នកសំរបសំរួលអាចដាក់ក្នុងការពិភាក្សាជាមួយសិក្ខាកាម ឬ បើអាចឆ្លើយបានទៅនឹងអនុសាសន៍ទាំងនោះ អ្នកសំរបសំរួលអាចឆ្លើយតបបាន។

*កំនត់ចំណាំ: រាល់សំនួរ និង អនុសាសន៍នានាដែលបានលើកឡើងដោយសិក្ខាកាមនៅក្នុងវគ្គនិមួយៗ មានសារៈសំខាន់ណាស់ ដែលអាចយកមកកែលំអមេរៀននិមួយ ៗ។ ដូច្នេះអ្នកសំរបសំរួលត្រូវកត់ត្រាទុកទាំងអស់ ហើយយកមកកែលំអមេរៀនអោយ បាន ល្អ និង សមស្រប។*

*សូមមើលផ្នែកទី៧ ទំព័រទី ៨៣ និង បទបង្ហាញ លេខ....*